**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការផ្តល់សេវាផ្នែកហានិភ័យការងារ របស់បេឡាជាតិរបបសន្តិសុខសង្គម នៅរាជធានីភ្នំពេញ ឆ្នាំ២០១៩

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អ៊ីង គឹមលេង**

លោក **សឿ ខេង៖**

សាស្ត្រាចារ្យណែនាំ

លោកស្រី **យឹម ម៉ាណែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៣ (បង់ថ្លៃ)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរ ឈ្មោះ **អ៊ីវ គឹមលេខ** និង **សឿ ទេវ៉ៈ** ដែលជានិស្សិតរដ្ឋបាលសាធារណៈ ជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយក្រាបប្រណិប័តន៍ សម្ដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណទាំងទ្វេគឺ លោកឪពុក **អ៊ាន លឹមសេខ** អ្នកម្ដាយ **ខឹម សុភាព** និង លោកឪពុក **សឿ ឡូញ** អ្នកម្ដាយ **ហេខ គឹមហេន** ដែលបានផ្ដល់កំណើត និងយកចិត្តទុកដាក់បីបាច់ ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនតាំងពីតូចរហូតដល់ធំ លះបង់ទាំងកម្លាំងកាយ កម្លាំងចិត្តដោយមិនខ្លាចនឿយហាត់ដើម្បីឱ្យតែកូនបានល្អ ជាពិសេសទៀតនោះ លោកទាំងពីរតែងតែទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងសម្ភារៈ ព្រមទាំងបានផ្ដល់ឱកាសដ៏មានតម្លៃឱ្យកូនៗបានសិក្សារៀនសូត្រក្រេបជញ្ជក់ចំណេះដឹងរហូតធ្វើឱ្យកូនអាចមានឱកាសក្នុងការសរសេរសារណាមួយនេះ នេះជាគុណូបការៈយ៉ាងវិសេសវិសាល និងថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបាន របស់លោកអ្នកមានគុណទាំងទ្វេ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្ដម **អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ដែលបានអនុញ្ញាតឱ្យខ្ញុំទាំងពីរបានចុះស្រាវជាវឯកសារនៅបេឡាជាតិរបបសន្តិសុខសង្គម។

សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោកស្រីសាស្ត្រាចារ្យ **ឃឹម ម៉ាណែត** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីធ្វើការដឹកនាំសរសេរសារណាមួយនេះ ដោយបានបង្ហាត់បង្រៀន ណែនាំ កែតម្រូវ និងបានផ្ដល់នូវគំនិតទស្សនៈល្អៗ រហូតដល់ខ្ញុំបាទទាំងពីរនាក់ អាចបញ្ចប់នូវការសរសេរសារណាមួយនេះដោយជោគជ័យគួរជាទីមោទនៈ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ គណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបណ្ដុះបណ្ដាលយើងខ្ញុំទាំងពីរ រួមទាំងនិស្សិតដទៃទៀតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុស័ក្ដិសិទ្ធិក្នុងលោកតាមបីបាច់ថែរក្សា និងប្រសិទ្ធិពរជ័យ សិរីមង្គល បវរមហាប្រសើរ ជូនចំពោះ អ្នកមានគុណទាំងទ្វេ គណៈគ្រប់គ្រងសាកលវិទ្យាល័យ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាស្តីពី **ការផ្តល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩** វាជាកិច្ចការស្រាវជ្រាវមួយ សម្រាប់យើងខ្ញុំទាំងពីរនាក់ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ បន្ទាប់ពីបានសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមក។ ការសរសេរសារណាមួយនេះ វាបានជួយឱ្យខ្ញុំទាំងពីរ បានធ្វើការសិក្សាស្វែងយល់ និងទទួលបានបទពិសោធន៍ថ្មីៗជាច្រើន ទាំងវិធីសាស្ត្រនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការសរសេរ ការប្រមូលទិន្នន័យដែលមានប្រភពច្បាស់លាស់ និងប្រភពឯកសារផ្សេងៗជាច្រើនទៀត ទាំងឯកសារមានស្រាប់ និងមិនទាន់មាន ដែលតម្រូវឱ្យមានការចុះយកទិន្នន័យដោយផ្ទាល់ និងតាមរយៈការសម្ភាសជាដើម។

នៅក្នុងសារណាមួយនេះវាបានបង្ហាញអំពីតួនាទី និងសារៈសំខាន់របស់បេឡាជាតិរបបសន្តិសុខសង្គម ទៅលើការផ្តល់សេវាផ្នែកហានិភ័យការងារ (សេវាចម្បងមួយក្នុងចំណោមសេវាមួយចំនួនទៀតរបស់គ្រឹះស្ថានមួយនេះ) ដើម្បីធានាសន្តិសុខប្រាក់ចំណូលជាមូលដ្ឋាន ជូនកម្មករនិយោជិត ក៏ដូចជាអ្នកនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់។ បន្ថែមពីនេះ វាក៏បានរៀបរាប់ពីលក្ខណៈទូទៅមួយចំនួនរបស់បេឡាជាតិរបបសន្តិសុខសង្គម នីតិវិធី ព្រមទាំងលក្ខខណ្ឌផ្សេងៗដើម្បីទទួលបានតាវកាលិកពីសេវាផ្នែកហានិភ័យការងារ។

មូលហេតុចំបងដែលនាំឱ្យមានការសរសេរសារណានេះ ដោយសារតែខ្ញុំទាំងពីរនាក់យល់ឃើញថា ការផ្តល់សេវាផ្នែកហានិភ័យការងារ គឺជារឿងដ៏សំខាន់មួយដែលបុគ្គលគ្រប់រូបគួរស្វែងយល់ពីវា ជាពិសេសបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលជាអ្នកមានសិទ្ធិក្នុងការទទួលយកសេវាទាំងនេះ។ យើងខ្ញុំទាំងពីរសង្ឃឹមយ៉ាងមុតមាំថាសារណានេះ នឹងអាចចូលរួមចំណែកក្នុងការផ្សព្វផ្សាយ និងផ្តល់ជាឯកសារពិគ្រោះមួយចំនួនចំពោះបុគ្គលដែលមានសិទ្ធិក្នុងការទទួលយកសេវាទាំងនោះ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមអធ្យាស្រ័យរាល់កំហុសខុសឆ្គងទាំងឡាយណាដែលអាចកើតមានឡើងដោយអចេតនា នៅក្នុងការសរសេរសារណាមួយនេះ ទាំងអក្ខរាវិរុទ្ធ វេយ្យាករណ៍ ពាក្យពេចន៍ អត្ថន័យ និងខ្លឹមសារដែលមិនគប្បីនានា។ យើងខ្ញុំសូមទទួលយកនូវមតិរិះគន់ និងគំនិតយោបល់ទាំងឡាយ ពីសំណាក់សាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីស្ថាបនា កែលម្អ ដោយក្តីសោមនស្សរីករាយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ........................................ ៣

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........................................ ៤

**ជំពូកទី ១**

**បេឡាជាតិរបបសន្តិសុខសង្គម**

**ផ្នែកទី ១ ៖ សញ្ញាណទូទៅរបស់បេឡាជាតិរបបសន្តិសុខសង្គម** ........................................ ៥

កថាខណ្ឌទី ១ ៖ សាវតាររបស់បេឡាជាតិរបបសន្តិសុខសង្គម ........................................ ៥

កថាខណ្ឌទី ២ ៖ គោលបំណង និងសារៈប្រយោជន៍របស់បេឡាជាតិរបបសន្តិសុខសង្គម ........................................ ៦

ក. គោលបំណង ........................................ ៦

ខ. សារៈប្រយោជន៍ ........................................ ៦

**ផ្នែកទី ២ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់បេឡាជាតិរបបសន្តិសុខសង្គម** ........................................ ៨

កថាខណ្ឌទី ១ ៖ ក្រុមប្រឹក្សាភិបាល ........................................ ៨

ក. សមាសភាពក្រុមប្រឹក្សាភិបាល ........................................ ៨

ខ. ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាល ........................................ ៩

គ. លក្ខខណ្ឌនៃការជ្រើសរើសសមាសភាពនៃក្រុមប្រឹក្សាភិបាល ........................................ ១០

ឃ. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ........................................ ១០

ង. ការបាត់បង់សមាជិកភាព ........ ១១
កថាខណ្ឌទី ២ ៖ អង្គការប្រតិបត្តិ ........ ១២
ក. នាយកនៃបេឡាជាតិរបបសន្តិសុខសង្គម ........ ១២
ខ. ភារកិច្ចរបស់នាយកបេឡាជាតិរបបសន្តិសុខសង្គម ........ ១២
គ. បុគ្គលិកបេឡាជាតិរបបសន្តិសុខសង្គម ........ ១៣
**ផ្នែកទី៣ ៖ ភារកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់បេឡាជាតិរបបសន្តិសុខសង្គម** ... ១៣
កថាខណ្ឌទី ១ ៖ ភារកិច្ចរបស់បេឡាជាតិរបបសន្តិសុខសង្គម ........ ១៣
កថាខណ្ឌទី ២ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់បេឡាជាតិរបបសន្តិសុខសង្គម ........ ១៤
ក. កិច្ចការគណនេយ្យ ........ ១៤
ខ. ប្រភពធនធាន ........ ១៥
គ. ការចំណាយ ........ ១៦
ឃ. ប្រាក់ត្រៀមបម្រុង ........ ១៦
ង. មូលនិធិបង្វិល ........ ១៧
ច. ការវិភាគសន្តិសុខសង្គម ........ ១៧
**ជំពូកទី ២**
**ដំណើរប្រព្រឹត្តទៅនៃការផ្តល់សេវាផ្នែកហានិភ័យការងាររបស់**
**បេឡាជាតិរបបសន្តិសុខសង្គម**
**ផ្នែកទី១ ៖ ការចុះបញ្ជិកា និងការបង់ភាគទាន** ........ ១៨
កថាខណ្ឌទី១ ៖ ការចុះបញ្ជិកា ........ ១៨
ក. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ........ ១៨
ខ. នីតិវិធី និងបែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបញ្ជិកាកម្មករនិយោជិត ........ ១៩
គ. អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ........ ២០
ឃ. របាយការណ៍កម្មករនិយោជិត ........ ២១

កថាខណ្ឌទី ២ ៖ ការបង់ភាគទាន ........ ២១

ក. កាតព្វកិច្ច និងអត្រានៃការបង់ភាគទាន ........ ២១

ខ. កាលបរិច្ឆេទនៃការបង់ភាគទាន ........ ២៣

គ. នីតិវិធី និងបែបបទបង់ភាគទាន ........ ២៣

ឃ. ការត្រួតពិនិត្យសៀវភៅបើកប្រាក់ និងបញ្ជីឈ្មោះកម្មករនិយោជិត ........ ២៤

**ផ្នែកទី២ ៖ ការផ្តល់សេវាផ្នែកហានិភ័យការងារ** ........ ២៤

កថាខណ្ឌទី ១ ៖ ការទទួលបានសេវាហានិភ័យការងារ ........ ២៤

ក. លក្ខខណ្ឌដែលចាត់ទុកជាគ្រោះថ្នាក់ការងារ ........ ២៤

ខ. សិទ្ធិទទួលបានសេវា ........ ២៥

គ. ការជូនដំណឹងហានិភ័យការងារ ........ ២៥

ឃ. ការអង្កេតហានិភ័យការងារ ........ ២៦

កថាខណ្ឌទី២ ៖ តាវកាលិកហានិភ័យការងារ ........ ២៧

ក. ការផ្តល់សេវាសង្គ្រោះបន្ទាន់ ........ ២៧

ខ. ការផ្តល់សេវាថែទាំ និងព្យាបាល ........ ២៧

គ. តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ........ ២៧

ឃ. តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ........ ២៨

ង. វិភាជន៍ជាសោហ៊ុយបូជាសព ........ ២៩

ច. តាវកាលិកឧត្តរជីវី ........ ២៩

ឆ. សេវាបុននីតិសម្បទា ........ ៣១

## ជំពូកទី ៣

## បញ្ហាប្រឈម និងដំណោះស្រាយ

**ផ្នែកទី ១ ៖ បញ្ហាប្រឈម** ........ ៣២

កថាខណ្ឌទី ១ ៖ ចំពោះនិយោជក សហគ្រាស គ្រឹះស្ថាន និងនិយោជិត ........ ៣២
ក. និយោជក សហគ្រាស គ្រឹះស្ថានមួយចំនួន ........ ៣២
ខ. និយោជិត ........ ៣២
កថាខណ្ឌទី ២ ៖ ចំពោះសេវាសុខាភិបាល ........ ៣៣
កថាខណ្ឌទី ៣ ៖ ចំពោះបេឡាជាតិរបបសន្តិសុខសង្គម ........ ៣៣
**ផ្នែកទី ២ ៖ ដំណោះស្រាយ** ........ ៣៤
កថាខណ្ឌទី១ ៖ ចំពោះនិយោជក សហគ្រាស គ្រឹះស្ថាន និងនិយោជិត ........ ៣៤
ក. និយោជក សហគ្រាស គ្រឹះស្ថានមួយចំនួន ........ ៣៤
ខ. និយោជិត ........ ៣៤
កថាខណ្ឌទី ២ ៖ ចំពោះសេវាសុខាភិបាល ........ ៣៥
កថាខណ្ឌទី ៣ ៖ ចំពោះបេឡាជាតិរបបសន្តិសុខសង្គម ........ ៣៥
**ផ្នែកទី ៣ ៖ វឌ្ឍនភាពនៃការផ្តល់សេវារបស់បេឡាជាតិរបបសន្តិសុខសង្គម** ........ ៣៦
កថាខណ្ឌទី ១ ៖ កំណែទម្រង់ ........ ៣៦
ក. ការងារព័ត៌មានវិទ្យា ........ ៣៦
ខ. ការងារសវនកម្មផ្ទៃក្នុង ........ ៣៦
កថាខណ្ឌទី ២ ៖ សមិទ្ធផល ........ ៣៦
**សេចក្តីសន្និដ្ឋាន** ........ ៣៧
**អនុសាសន៍** ........ ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ពេញមួយសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម កម្ពុជាបានស្គាល់នូវភាពវិនាសហិនហោចជាងសម័យណាៗទាំងអស់ តាមរយៈការកាប់សម្លាប់ប្រជាពលរដ្ឋ និងការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងទៅលើគ្រប់វិស័យដែលជាមូលដ្ឋានគ្រឹះរបស់ប្រទេសជាតិ ក្នុងនោះវិស័យសន្តិសុខសង្គម ក៏មិនខុសពីវិស័យផ្សេងៗដែរ ដែលបានទទួលរងពីការបំផ្លិចបំផ្លាញក្នុងសម័យមួយនេះ។ ក្រោយពីថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យមួយនេះត្រូវបានស្តារឡើងវិញជាបណ្តើរៗ ដោយនៅក្នុងឆ្នាំ១៩៩២ ច្បាប់ស្តីពីការងារត្រូវបានអនុម័តឡើង និងរៀបចំឡើងវិញនៅក្នុងឆ្នាំ១៩៩៧ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើនៅឆ្នាំ២០០២។ ជាពិសេស ការប្រកាសឱ្យដំណើរការជាផ្លូវការរបស់ បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា កាលពីឆ្នាំ២០០៨។

ចំពោះប្រធានបទ **ការផ្តល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គមនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩** គឺមានសារៈសំខាន់ក្នុងការលើកកម្ពស់សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ របស់កម្មករនិយោជិត ក៏ដូចជាជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់។

ទោះបីជា **ប.ស.ស** ត្រូវបានប្រកាសឱ្យដំណើរការជាផ្លូវការតាំងពីឆ្នាំ២០០៨ក្តី ក៏ប៉ុន្តែនៅតែមានកម្មករនិយោជិត និងអ្នកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារមួយចំនួនហាក់បីដូចជាមិនទាន់យល់ច្បាស់អំពីសារប្រយោជន៍អ្វីខ្លះដែលខ្លួនត្រូវទទួលបាន ជាពិសេសសេវាសន្តិសុខសង្គមផ្នែកហានិភ័យការងាររបស់ **ប.ស.ស** ហើយមានលក្ខខណ្ឌអ្វីខ្លះដើម្បីទទួលបានសេវានោះ ពេលខ្លះមិនបានដឹងវាជាសិទ្ធិដែលខ្លួនត្រូវទទួលបានពីនិយោជក ដែលបានកំណត់ដោយច្បាប់ការងារទៀតផង។ នៅក្នុងប្រធានបទនេះ ខ្ញុំសង្ឃឹមថានឹងបានចូលរួមចំណែកចែករំលែកចំណេះដឹងដល់កម្មករនិយោជិត ក៏ដូចជាអ្នកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់ឱ្យបានយល់ច្បាស់ អំពីសេវាផ្នែកហានិភ័យការងាររបស់ **ប.ស.ស** និងបែបបទផ្សេងៗដើម្បីទទួលបានសេវានេះ មួយវិញទៀតសារណាមួយនេះក៏អាចផ្តល់ជាឯកសារពិគ្រោះមួយចំនួនដល់សិស្សប្អូនជំនាន់ក្រោយ ឬក៏អ្នកដែលមានចំណាប់អារម្មណ៍ចង់ស្វែងយល់ទៅលើប្រធានបទមួយនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ហានិភ័យការងារ គឺជាបញ្ហាចម្បងមួយក្នុងចំណោមបញ្ហាផ្សេងៗជាច្រើនរបស់កម្មករនិយោជិត និងអ្នកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់កំពុងជួបប្រទះ ដែលត្រូវដោះស្រាយជូនពួកគាត់ ហើយបញ្ហាមួយនេះវាមិនមែនជាបញ្ហាដែលទើបតែកើតឡើងថ្មីៗនោះទេ តាមពិតទៅវាជាបញ្ហាដែលចាក់ស្រេះ

តាំងពីប្រវត្តិសាស្ត្រមនុស្សជាតិមកម្ល៉េះ។ ហេតុដូច្នេះបានរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការបង្កើតគ្រឹះស្ថានសាធារណៈមួយឡើង នោះគឺបេឡាជាតិរបបសន្តិសុខសង្គមដើម្បីជួយសម្រួល និងដោះស្រាយបញ្ហានេះជូន កម្មករនិយោជិត ក៏ដូចជាអ្នកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់។

នៅក្នុងកិច្ចការស្រាវជាវមួយនេះបានលេចឡើងនូវសំណួរមួយចំនួនដូចជាៈ

១. តើអ្វីទៅជា **ប.ស.ស**? ហើយ **ប.ស.ស** បង្កើតឡើងក្នុងគោលបំណងអ្វី?

២. តើនរណាដែលជាគោលដៅចម្បងរបស់ **ប.ស.ស**?

៣. តើសេវាសន្តិសុខសង្គមផ្នែកហានិភ័យការងារជាអ្វី? មានលក្ខន្តិកៈអ្វីខ្លះដើម្បីទទួលបានសេវានេះ? ហើយវាបានផ្តល់ផលប្រយោជន៍អ្វីខ្លះ ចំពោះបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីការងារទាំងអស់?

៤. ឆ្លងតាមការអនុវត្តកន្លងមក តើការផ្តល់សេវាផ្នែកហានិភ័យការងាររបស់ **ប.ស.ស** សម្រេចបានសមិទ្ធផលយ៉ាងណាហើយ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជាវទៅលើប្រធានបទមួយនេះគឺដើម្បីៈ

១. ជួយផ្សព្វផ្សាយអំពីសារៈប្រយោជន៍ផ្សេងៗរបស់ **ប.ស.ស** ឱ្យបានទូលំទូលាយជាពិសេសទៅលើការផ្តល់សេវាផ្នែកហានិភ័យការងារ។

២. ស្វែងយល់ពីនីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗដើម្បីទទួលបានសេវាសន្តិសុខសង្គមផ្នែកហានិភ័យការងាររបស់ **ប.ស.ស** ។

៣. លើកកម្ពស់ការយល់ដឹងជាសាធារណៈដល់សាធារណៈជន ជាពិសេសចំពោះកម្មករនិយោជិត ក៏ដូចជាបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារទាំងអស់ អំពីសេវាផ្នែកហានិភ័យការងារ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃសារណាទៅលើប្រធានបទមួយនេះ គឺផ្តោតសំខាន់ទៅលើការផ្តល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គមនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩ ចំពោះបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារតែប៉ុណ្ណោះ ចំណែកឯបុគ្គលមុខងារសាធារណៈមិនត្រូវលើកយកមកធ្វើការបកស្រាយនៅក្នុងសារណាមួយនេះឡើយ។ នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ មានទំនាក់ទំនងជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាពិសេសនោះគឺ គ្រឹះស្ថានសាធារណៈបេឡាជាតិរបបសន្តិសុខសង្គមផ្ទាល់តែម្តង ដែលជាអ្នកមានសមត្ថកិច្ច និងទទួលខុសត្រូវក្នុងការផ្តល់សេវា។ ចំណែកឯលិខិតបទដ្ឋានគតិយុត្តដែលយកមកធ្វើជាសំអាងក្នុងការសរសេរមានដូចជា ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម

បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ប្រកាសរួមស្តីពីការជូនដំណឹងហានិភ័យការងារ ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ និងលទ្ធផលរបាយការណ៍ដែលទទួលបានពីការចុះស្រាវជ្រាវនៅបេឡាជាតិរបបសន្តិសុខសង្គម។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់មួយចំនួនដែលមានបង្កប់នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះមាន ៖

១. ចំពោះសង្គម ៖ បានជួយលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីសារៈប្រយោជន៍របស់បេឡាជាតិរបបសន្តិសុខសង្គមក្នុងការផ្តល់សេវាផ្នែកហានិភ័យការងារ។

២. ចំពោះ **ប.ស.ស** ៖ ជួយផ្សព្វផ្សាយអំពី តួនាទី និងចក្ខុវិស័យរបស់ **ប.ស.ស** ក្នុងដំណើរការផ្តល់សេវាផ្នែកហានិភ័យការងារ។

៣. ចំពោះអ្នកនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ៖ ជួយឱ្យពួកគាត់យល់កាន់តែច្បាស់ថាអ្វីទៅជា **ប.ស.ស** ជាពិសេសទាក់ទងនឹងសេវាសន្តិសុខសង្គមផ្នែកហានិភ័យការងារដែលគាត់ត្រូវទទួលបាន។

៤. ចំពោះសិស្សប្អូនជំនាន់ក្រោយ ឬអ្នកដែលចង់ស្វែងយល់លើប្រធានបទនេះ ៖ ផ្តល់ជាឯកសារពិគ្រោះក្នុងការស្រាវជ្រាវ។

៥. ចំពោះខ្ញុំផ្ទាល់ ៖ បានសិក្សាស្វែងយល់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ **ប.ស.ស** សិក្សាស៊ីជម្រៅលើការផ្តល់សេវាផ្នែកហានិភ័យការងារ រួមជាមួយបទពិសោធន៍មួយចំនួនតាមរយៈការចុះយកទិន្នន័យដោយផ្ទាល់នៅ **ប.ស.ស** និងតាមរយៈការសម្ភាសជាដើម។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវប្រធានបទនេះមានភាពច្បាស់លាស់ ប្រាកដប្រជា និងអាចទុកចិត្តបាន គឺត្រូវពឹងផ្អែកទៅលើការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។

**ការកំណត់អថេរ**

ជាបឋមយើងត្រូវកំណត់អថេរជាមុនសិន ដើម្បីកំណត់គោលដៅក្នុងការស្វែងរកទិន្នន័យ។ អថេរមានពីរគឺ អថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

- អថេរឯករាជ្យមាន៖ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម របាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ របស់ **ប.ស.ស** និងសេចក្តីជូនដំណឹងមួយចំនួនដែលចេញដោយបេឡាជាតិរបបសន្តិសុខសង្គម។

- អថេរមិនឯករាជ្យមាន៖ ការចុះសាកសួរ ទិន្នន័យ និងព័ត៌មានផ្សេងៗពីមន្ត្រីដែលបម្រើការងារនៅគ្រឹះស្ថានសាធារណៈ **ប.ស.ស** និងកម្មករនិយោជិត ក៏ដូចជាអ្នកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។

**ការប្រមូលទិន្នន័យ**

នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ខ្ញុំបាទបានធ្វើការប្រមូលទិន្នន័យដែលមានស្រាប់ និងមិនទាន់មានមកធ្វើការវិភាគ។ ទិន្នន័យដែលមានស្រាប់ គឺបានមកពី លិខិតបទដ្ឋានគតិយុត្តនានា គេហទំព័រផ្លូវការរបស់ **ប.ស.ស** ឯកសារតាមបណ្ណាល័យ បណ្ណាគារ និងគេហទំព័រមួយចំនួនទៀត។ ចំណែកឯទិន្នន័យដែលមិនទាន់មាន គឺបានមកពីការចុះសាកសួរមន្ត្រីដែលបម្រើការងារនៅ **ប.ស.ស** និងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

**ការវិភាគទិន្នន័យ**

រាល់ទិន្នន័យដែលប្រមូលបានត្រូវយកមកធ្វើការវិភាគតាមបែបពិពណ៌នា និងធ្វើការប្រៀបធៀបគ្នារវាងទិន្នន័យដែលមានស្រាប់ និងទិន្នន័យដែលបានមកពីការសម្ភាស ដើម្បីធ្វើការវាយតម្លៃរួមទៅលើប្រធានបទមួយនេះ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ជាដំបូងនៃសារណាមួយនេះបាននិយាយអំពី សេចក្ដីផ្ដើមនៃប្រធានបទដោយមានធាតុផ្សំដូចជា លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈប្រយោជន៍នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ចំណែកឯខ្លឹមសារនៃប្រធានបទមានបីជំពូកគឺ៖

**ជំពូកទី ១ ៖ បេឡាជាតិរបបសន្តិសុខសង្គម**

**ជំពូកទី ២ ៖ ដំណើរប្រព្រឹត្តទៅនៃការផ្ដល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម**

**ជំពូកទី៣ ៖ បញ្ហាប្រឈម និងដំណោះស្រាយ**

# ជំពូកទី ១

# បេឡាជាតិរបបសន្តិសុខសង្គម

# ជំពូកទី ១

# បេឡាជាតិរបបសន្តិសុខសង្គម

## ផ្នែកទី ១ ៖ សញ្ញាណទូទៅរបស់បេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាកម្មសាធារណៈតាមបែបបទលក្ខណៈសង្គម ដែលមានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ **"ប.ស.ស"**។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយ **ប.ស.ស** មានទីស្នាក់ការកណ្តាលនៅក្នុងរាជធានីភ្នំពេញ។[1] ជាពិសេស **ប.ស.ស** ជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ហើយស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[2]

### កថាខណ្ឌទី ១ ៖ សាវតារបស់បេឡាជាតិរបបសន្តិសុខសង្គម

**ប.ស.ស** បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៥៥ ដោយយោងទៅតាមអនុក្រឹត្យលេខ៥៥ និង៣០៦។ ប៉ុន្តែគួរអោយសោកស្តាយក្នុងកំឡុងរបបប្រល័យពូជសាសន៍ឆ្នាំ១៩៧៥ ដល់ ១៩៧៩ របបនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ នៅក្នុងឆ្នាំ១៩៧៩ ដល់ ១៩៩៣ ប្រជាពលរដ្ឋទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ បន្ទាប់ពីបានបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះទទួលខុសត្រូវការរៀបចំទាំងអស់នៃប្រកាសសម្រាប់ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាពលរដ្ឋ ដែលធ្វើការក្នុងវិស័យឯកជន។ ជាលទ្ធផលនៃការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារឆ្នាំ១៩៩២ ដែលជាច្បាប់ការងារកម្ពុជាបច្ចុប្បន្ន ដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ ( ថ្មីៗនេះបានផ្លាស់ប្តូរទៅជាអគ្គនាយកដ្ឋានការងារ )។ ចាប់តាំងពីពេលនោះមក ច្បាប់សន្តិសុខសង្គមត្រូវបានអនុម័តដោយសភានៅខែកញ្ញា ឆ្នាំ២០០២ ដែលថ្មីៗនេះត្រូវបានគេស្គាល់ថា ច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរការងារ។ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានអនុម័តនៅឆ្នាំ២០០៧ ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ **ប.ស.ស** ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារសន្តិសុខសង្គមឱ្យស្របទៅតាមច្បាប់សន្តិសុខសង្គម

[1] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១

[2] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២

ជាតិ និងអនុក្រឹត្យសន្តិសុខសង្គម ។ ក្រោយពីការរៀបចំដ៏ធំទូលាយនេះ **ប.ស.ស** ត្រូវបានដំណើរការនៅចុងឆ្នាំ ២០០៨។[3]

### កថាខណ្ឌទី ២ ៖ គោលបំណង និងសារៈប្រយោជន៍របស់បេឡាជាតិរបបសន្តិសុខសង្គម

**ក. គោលបំណង**

**ប.ស.ស** មានគោលបំណងដូចខាងក្រោម ៖

- រៀបចំ និងគ្រប់គ្រងរបបសន្តិសុខសង្គមយោងតាមបទប្បញ្ញត្តិ នៃច្បាប់ដែលបានបង្កើតរបបសន្តិសុខសង្គមនេះសម្រាប់ជនទាំង ឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ធានាការផ្តល់តាវកាលិកដល់សមាជិក **ប.ស.ស** ក្នុងគោលបំណងផ្តល់ឱ្យសមាជិកនូវសន្តិសុខប្រាក់ចំណូលក្នុងករណីដែលសមាជិករូបនោះ មានយថាភាពមួយចំនួនដូចជា ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និងគ្រោះថ្នាក់មួយចំនួនទៀត
- ប្រមូលភាគទានពីសមាជិក និងនិយោជកទាំងអស់
- ជួយសម្រួល និងរៀបចំបទប្បញ្ញត្តិនៃសេវាសង្គម និងសុខភាពជូនសមាជិកទាំងអស់
- សហប្រតិបត្តិការជាមួយអង្គការនានាដែលទាក់ទងទៅនឹង៖
    - អប់រំ និងផ្សព្វផ្សាយយុទ្ធសាស្ត្រក្នុងការការពារហានិភ័យការងារ
    - និង ផ្សព្វផ្សាយវិធានការស្តីពីសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ
- សហប្រតិបត្តិការជាមួយនឹងអង្គការពាក់ព័ន្ធដើម្បីសិក្សា និងស៊ើបអង្កេតជំងឺវិជ្ជាជីវៈ
- គ្រប់គ្រងការវិនិយោគនៃមូលនិធិសន្តិសុខសង្គម។[4]

**ខ. សារៈប្រយោជន៍**

បេឡាជាតិរបបសន្តិសុខសង្គម គឺជាគ្រឹះស្ថានសាធារណៈមួយដែលបង្កើតឡើងដើម្បីជួយសម្រួលដល់ការលំបាករបស់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។

**ប.ស.ស** មានសារៈប្រយោជន៍ដូចជា ៖

- ធានាកម្រិតជីវភាពគ្រួសាររបស់កម្មករនិយោជិតនៅពេលដែលរងហានិភ័យនានា
- លើកកម្ពស់គុណភាពបរិមាណផលិតផលសហគ្រាសតាមរយៈការជឿជាក់លើការងារ
- រួមចំណែកលើកកម្ពស់សុខភាពកម្មករនិយោជិត តាមរយៈការចូលរួមភាគទានសង្គម
- លើកស្ទួយសមធម៌ សាមគ្គីធម៌ និងយុត្តិធម៌ក្នុងសង្គម តាមរយៈការរំលែកហានិភ័យនានា

[3] ប្រវត្តិសង្ខេប, អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី០៧ មិថុនា ២០២០)

[4] គោលបំណង, អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី០៧ មិថុនា ២០២០)

- ធានាសិទ្ធិជាមូលដ្ឋានរបស់មនុស្សជាតិជាពិសេសកម្មករនិយោជិតដែលមានចែងក្នុងច្បាប់
- កម្មករនិយោជិតមានក្តីសង្ឃឹមលើការងារក្នុងវិស័យឯកជន ដោយសារពួកគេយល់ឃើញថា មានការធានារ៉ាប់រងនៅពេលជួបហានិភ័យសង្គមនានា ដូចមន្ត្រីរាជការរដ្ឋដែរ
- កម្មករនិយោជិតទទួលបានការងារប្រពៃ តាមរយៈការលើកកម្ពស់លក្ខខណ្ឌការងារ ជាពិសេសសុវត្ថិភាពការងារ និងអនាម័យការងារតាមសហគ្រាស គ្រឹះស្ថាន
- ធ្វើឱ្យមានសុខដុមរមណីយកម្មក្នុងសង្គមជាតិ ជាពិសេសកម្មករនិយោជិត និងនិយោជក
- ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម តាមរយៈការវិនិយោគប្រាក់ដែលនៅសល់ពីការប្រើប្រាស់សម្រាប់តាវកាលិក
- ចូលរួមចំណែកកសាងនីតិរដ្ឋ ព្រមទាំងលើកស្ទួយកម្មវិធីកំណែទម្រង់នយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ឆាប់ទទួលបានជោគជ័យ
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលមានចែងក្នុងចតុកោណទី៣ មុំទី៤ ទទួលបានជោគជ័យតាមការកំណត់
- និយោជកត្រូវបានបំពេញករណីយកិច្ចគុណធម៌ ដោយចែករំលែកតាមរយៈ កាតព្វកិច្ចបង់ភាគទានសម្រាប់របបសន្តិសុខសង្គម
- ធានានិរន្តរភាពដល់ជីវភាពរស់នៅរបស់កម្មករនិយោជិតនៅពេលបច្ចុប្បន្នក៏ដូចជានៅពេលអនាគត។[5]

[5] សំណួរ និង ចម្លើយ. សំណួរទី៩, អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី០៧ មិថុនា ២០២០)

## ផ្នែកទី ២ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់បេឡាជាតិរបបសន្តិសុខសង្គម




បេឡាជាតិរបបសន្តិសុខសង្គម គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជានីតិបុគ្គលសាធារណៈ មានស្វ័យភាពខាងហិរញ្ញវត្ថុ ដែលមានបេសកកម្ម បម្រើសេវាផ្នែកសាធារណៈរដ្ឋបាលមានលក្ខណៈសង្គមស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាណាព្យាបាល ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ **ប.ស.ស** ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើត **ប.ស.ស** ក៏ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារផងដែរ។[6]

### កថាខណ្ឌទី ១ ក្រុមប្រឹក្សាភិបាល

**ប.ស.ស** ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថាន ក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងក្នុងក្របខណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស**។[7]

#### ក. សមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ **ប.ស.ស** មានសមាសភាពដូចខាងក្រោម៖

- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ០១រូប ប្រធាន

---

[6] រចនាសម្ព័ន្ធ,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី០៧ មិថុនា ២០២០)

[7] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៤

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន ០១រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ០១រូប សមាជិក
- នាយកនៃ **ប.ស.ស.** ០១រូប សមាជិកស្វ័យប្រវត្តិ
- តំណាងនិយោជក ០២រូប សមាជិក
- តំណាងកម្មករនិយោជិត ០២រូប សមាជិក។[8]

**ខ. ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យ ដំណើរការប្រព្រឹត្តទៅនៃ **ប.ស.ស.**។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចខាងក្រោម៖

- អនុម័តថវិកាប្រចាំឆ្នាំនៃ **ប.ស.ស** ជាពិសេសសម្រាប់តាវកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច
- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្ដីពីការគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចអង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខដំណែង ការដាក់ពិន័យ និងការផ្ដល់លាភការនៃបុគ្គល តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងការសម្រេចលើសំណើនៃការកំណត់ភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្ដីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាភិបាលបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។[9]

[8] អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៤

[9] អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៥

**គ. លក្ខខណ្ឌនៃការជ្រើសរើសសមាសភាពនៃក្រុមប្រឹក្សាភិបាល**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

តំណាងកម្មករនិយោជិត និងនិយោជក ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់ ឬអាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ។[10]

**ឃ. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣ (បី) ខែ។ ទោះជាមានការកំណត់យ៉ាងនេះក្តី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ប.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់នាយកនៃ **ប.ស.ស** ឬសមាជិកដែលមានចំនួន ០៥ (ប្រាំ) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ប.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ ( ហាសិប ) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិកក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិនបើខ្វះកូរ៉ុម ការប្រជុំត្រូវលើកទៅ ១៥ (ដប់ប្រាំ)ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើ

[10] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៦

របៀបវារៈដដែល។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះណាតែមានការអនុម័តដោយសំឡេងនៃសមាជិកភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។[11]

សេចក្ដីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ប.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០ (ដប់)ថ្ងៃ យ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសម្គាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាពីប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាមួយសម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងនោះ ក្នុងកំណត់ហេតុនៃការប្រជុំលើកចុងក្រោយនេះផង។[12]

**ខ. ការបាត់បង់សមាជិកភាព**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងករណីមួយចំនួនដូចខាងក្រោម៖

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬមានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ **ប.ស.ស** ឬបម្រើសេវាណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្ដី
- សមាជិករូបនោះត្រូវបានតុលាការផ្ដន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ បានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល។

សមាជិកក្រុមប្រឹក្សារូបណាដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវព្យួរការងារជាបណ្ដោះអាសន្ន។ ការជំនួសសមាជិកក្រុមប្រឹក្សាភិបាលដែលបានបាត់បង់សមាជិកភាពរបស់ខ្លួន ត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ។[13]

---

[11] អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៧

[12] អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៨

[13] អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១០

## កថាខណ្ឌទី ២ ៖ អង្គការប្រតិបត្តិ

### ក. នាយកនៃបេឡាជាតិរបបសន្តិសុខសង្គម

នាយកនៃ **ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃ **ប.ស.ស** មានភារកិច្ចចាត់ចែង គ្រប់គ្រងនិងការងារប្រចាំថ្ងៃរបស់ **ប.ស.ស**។[14]

នាយកនៃ **ប.ស.ស** ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃ **ប.ស.ស** ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។[15]

### ខ. ភារកិច្ចរបស់នាយកបេឡាជាតិរបបសន្តិសុខសង្គម

នាយកនៃ **ប.ស.ស** មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងារនៃ **ប.ស.ស**
- ទទួលបន្ទុកដឹកនាំ **ប.ស.ស** ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេស
- រៀបចំថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ដើម្បីដាក់ជូនក្រុមប្រឹក្សាពិបាលពិនិត្យ និងសម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបរបស់ **ប.ស.ស** ដោយគោរពតាមលក្ខន្តិកៈ ឬច្បាប់ជាធរមាន និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិករបស់ **ប.ស.ស** ដែលនៅក្រៅក្របខណ្ឌនៃមន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ **ប.ស.ស** ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ **ប.ស.ស** និងទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ **ប.ស.ស**។

នាយកនៃ **ប.ស.ស** មានសិទ្ធិផ្ទេរអំណាចខ្លះ ឬទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល។[16]

---

[14] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១១

[15] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១២

[16] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១២

**គ. បុគ្គលិកបេឡាជាតិរបបសន្តិសុខសង្គម**

គណនេយ្យករនៃ **ប.ស.ស** ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពគ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណនេយ្យករនេះ ត្រូវស្ថិតក្រោមឱវាទផ្ទាល់របស់នាយក **ប.ស.ស**។[17]

បុគ្គលិកអចិន្ត្រៃយ៍របស់ **ប.ស.ស** រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ **ប.ស.ស**។ មន្ត្រីទាំងនេះត្រូវទទួលបន្តប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។ បេឡាជាតិរបបសន្តិសុខសង្គមអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ឬកម្មករ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្របតាមច្បាប់ស្តីពីការងារ។

បុគ្គលិកនៃ **ប.ស.ស** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។[18]

## ផ្នែកទី ៣ ៖ ភារកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់បេឡាជាតិរបបសន្តិសុខសង្គម

### កថាខណ្ឌទី ១ ៖ ភារកិច្ចរបស់បេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបស់សន្តិសុខសង្គមមានភារកិច្ចមួយចំនួនដូចជា៖

- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមទៅតាមច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ
- ធានាឱ្យបានសមស្របនូវតារកាលិកទាំងឡាយសម្រាប់សមាជិកនៃ **ប.ស.ស** ក្នុងគោលបំណងជួយសម្រួលការលំបាកនានានៅពេលជរាភាពទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះដោយយថាហេតុផ្សេងៗទៀតដូចជាជំងឺ មាតុភាពជាដើម
- ប្រមូលភាគទានពីសមាជិកនៃ **ប.ស.ស** និងនិយោជក
- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន

[17] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៣

[18] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៥

- សហការជាមួយអង្គភាពដែលពាក់ព័ន្ធ ដើម្បីអប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និងអនាម័យការងារ
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម[19]
- ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗ ព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត
- ចុះបញ្ជី និងគ្រប់គ្រងលេខសម្គាល់សមាជិក **ប.ស.ស**
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស**
- អប់រំផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិក **ប.ស.ស**
- សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ
- សិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ
- ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល
- សិក្សាវិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម
- អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាព និងសង្គមដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍ផ្សេងៗនៃសមាជិក **ប.ស.ស**
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។[20]

## កថាខណ្ឌទី ២ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់បេឡាជាតិរបបសន្តិសុខសង្គម

### ក. កិច្ចការគណនេយ្យ

**ប.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍ គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កាលបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣១ ខែមីនា នៃការបរិច្ឆេទបន្ទាប់។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវសុំការយល់ព្រមពីរដ្ឋ

[19] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា៣

[20] ច្បាប់ស្តីពី របបសន្តិសុខសង្គម. លេខ នស/រកម/១១១៩/០១៨. ០២ វិច្ឆិកា ២០១៩. មាត្រា១៣

មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងកំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល។[21]

**ក១. ភារកិច្ចរបស់អាណាប័កដើមខ្សែ**

នាយកនៃ **ប.ស.ស** ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរដ្ឋទេយ្យចំណូល ឬបុរេប្រទានបានដោយការយល់ព្រមពីគណនេយ្យករ។[22]

**ក២. ភារកិច្ចគណនេយ្យករ**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់កាប់គណនេយ្យត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែគ្មានសំឡេងឆ្នោតឡើយ។[23]

គណនេយ្យករមានភារកិច្ចដូចជាៈ

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។[24]

**ខ. ប្រភពធនធាន**

ប្រភពធនធាននៃ **ប.ស.ស** មានដូចខាងក្រោមៈ

- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត **ប.ស.ស**
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន

[21] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៧

[22] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៨.១

[23] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៨.២

[24] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា១៨.៣

- ភាគទានរបស់សមាជិកនៃ **ប.ស.ស** និងនិយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម
- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ
- ផលចំណេញដែលបានមកពីការវិនិយោគ
- អំណោយ និងអច្ច័យទានផ្សេងៗ
- ប្រភពធនធានដទៃទៀតដែល **ប.ស.ស** អាចទទួលបានស្របតាមច្បាប់។[25]

**គ. ការចំណាយ**

ការចំណាយរបស់ **ប.ស.ស** រួមមាន៖

- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ
- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃផ្នែក **ប.ស.ស**
- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច
- ការចំណាយទៅលើការវិនិយោគដើម្បីជាប្រយោជន៍របស់ **ប.ស.ស**
- ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលម្អិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។[26]

**ឃ. ប្រាក់ត្រៀមបម្រុង**

ប្រាក់ត្រៀមបម្រុងអប្បបរមា សម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង១/២ ( មួយភាគពីរ ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល២ ( ពីរ )ឆ្នាំចុងក្រោយ។

ប្រាក់បម្រុងសម្រាប់ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីទទួលបានសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

អត្រាភាគទានដែលមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ត្រូវពិនិត្យឡើងវិញក្នុងករណីដែលប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗធ្លាក់ចុះទាបជាង កម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

---

[25] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២០

[26] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២១

ប្រាក់បម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា។[27]

**ខ. មូលនិធិបង្វិល**

មូលនិធិបង្វិលត្រូវបានគេបង្កើតឡើងសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម។ មូលនិធិនេះមិនត្រូវតិចជាង ២ (ពីរ) ដង នៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ **ប.ស.ស** នៅក្នុងកំឡុងឆ្នាំចុងក្រោយឡើយ។[28]

**ច. ការវិភាគសន្តិសុខសង្គម**

**ប.ស.ស** ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្តិសុខសង្គមយ៉ាងយូរ ៣ (បី) ឆ្នាំម្តង។ ក្នុងករណីដែលការវិភាគនេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ **ប.ស.ស** ត្រូវស្នើសុំធ្វើការកែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើរការរបស់ **ប.ស.ស**។ រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ស.ស** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា។[29]

[27] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២២
[28] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២៣
[29] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម. លេខ១៦ អនក្រ/បក. ០២ មីនា ២០០៧. មាត្រា២៤

# ជំពូកទី ២
# ដំណើរប្រព្រឹត្តទៅនៃការផ្តល់សេវា ផ្នែកហានិភ័យការងាររបស់បេឡាជាតិ របបសន្តិសុខសង្គម

# ជំពូកទី២

# ដំណើរប្រព្រឹត្តទៅនៃការផ្ដល់សេវាផ្នែកហានិភ័យរបស់ បេឡាជាតិរបបសន្តិសុខសង្គម

## ផ្នែកទី ១ ៖ ការចុះបញ្ជិកា និងការបង់ភាគទាន

### កថាខណ្ឌទី ១ ៖ ការចុះបញ្ជិកា

#### ក. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្ត នៃច្បាប់ស្ដីពីរបប សន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្ដីពីការងារត្រូវមានកាតព្វកិច្ច មកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។[30]

រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ៖

- ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរការ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីប្រកាសលេខ០២១/០៨ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង **ប.ស.ស** ចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាន នៃប្រកាសលេខ ០២១/០៨ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតក្នុង **ប.ស.ស** ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីកាល បរិច្ឆេទនៃការចាប់ផ្ដើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។[31]

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាសរបស់ខ្លួន មក **ប.ស.ស** ដើម្បីចុះបញ្ជិកាក្នុង **ប.ស.ស**។ ការផ្ញើបញ្ជីឈ្មោះកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នានឹង ការផ្ញើទម្រង់ បញ្ជិកាសហគ្រាស គ្រឹះស្ថាន។[32]

---

[30] ប្រកាសស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ០២១-០៨ កប/ប្រក. ១១ កុម្ភៈ ២០០៨. ប្រការ១.១

[31] ប្រកាសស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ០២១-០៨ កប/ប្រក. ១១ កុម្ភៈ ២០០៨. ប្រការ១.២

[32] ប្រកាសស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ០២១-០៨ កប/ប្រក. ១១ កុម្ភៈ ២០០៨. ប្រការ២

### ខ. នីតិវិធី និងបែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបញ្ជិកាកម្មករនិយោជិត

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថា ទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុង **ប.ស.ស**។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវធ្វើភ្ជាប់មកជាមួយនឹងទម្រង់"១.០១" នូវ "បញ្ជិកាពាណិជ្ជកម្ម" ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតតួបករណ៍គតិយុត្តសមមូលដទៃទៀត។[33]

ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើតាមនីតិវិធី និងបែបបទដូចខាងក្រោម៖

**ខ១. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស**

- ការចុះបញ្ជិកាកម្មករនិយោជិតត្រូវធ្វើតាមទម្រង់ សលាកបត្រព័ត៌មាន សម្រាប់ផ្ដល់អត្តសញ្ញាណសមាជិក **ប.ស.ស**
- **ប.ស.ស** នឹងផ្ដល់កាលបរិច្ឆេទសម្រាប់ការចុះកំណត់អត្តសញ្ញាណសមាជិក **ប.ស.ស** នៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថាន
- នាយក ឬម្ចាស់សហគ្រាសគ្រឹះស្ថានត្រូវមានកាតព្វកិច្ចបំពេញព័ត៌មានកម្មករនិយោជិតឱ្យបានត្រឹមត្រូវ នៅក្នុងសាលាកបត្រព័ត៌មាន ដោយភ្ជាប់មកជាមួយនូវឯកសារដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬប័ណ្ណស្នាក់នៅ ឬឯកសារផ្សេងៗដែលមានតម្លៃស្មើ
- **ប.ស.ស** នឹងផ្ដល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក **ប.ស.ស** ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង។[34]

**ខ២. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី**

- ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នា និងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

---

[33] ប្រកាសស្ដីពីការកែសម្រួលប្រការ ៣ ប្រការ ៤ និងប្រការ ៥ នៃប្រកាសលេខ ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ២៨៥ កប/ប្រក.១៨ វិច្ឆិកា ២០១៤. ប្រការ៣ ថ្មី

[34] ការងារបញ្ជីកា,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៤ មិថុនា ២០២០)

- សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ៥០នាក់ឡើង **ប.ស.ស** នឹងផ្តល់កាលបរិច្ឆេទចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត។ និយោជកត្រូវអនុវត្តកាតព្វកិច្ចដូចមាន ចែងនៅក្នុងចំណុចទី៣ នៃ**ខ១** ខាងលើ
- សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតក្រោម ៥០នាក់ **ប.ស.ស** នឹងផ្តល់កាលបរិច្ឆេទ និងអញ្ជើញនិយោជក ឬតំណាង និងកម្មករនិយោជិត មកកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅនឹង **ប.ស.ស** ដោយភ្ជាប់មកជាមួយនូវឯកសារដូចមានចែងក្នុងចំណុច **ក៣** ខាងលើ បន្ទាប់ពីបានបំពេញ សលាប័ត្រព័ត៌មានរួច
- **ប.ស.ស** នឹងផ្តល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក **ប.ស.ស** ជូនទៅកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង។[35]

**គ. អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

**ប.ស.ស** ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗបន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ សហគ្រាស គ្រឹះស្ថានមួយ ត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ដែលឱ្យឈ្មោះថា "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន"។

**ប.ស.ស** ត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច។ វិញ្ញាបនបត្រនេះ ចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និងកាលបរិច្ឆេទចុះបញ្ជិកា។ និយោជក ត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន។

បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាកម្មករនិយោជិត" បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណ និងចេញ "បណ្ណ័សមាជិក **ប.ស.ស**" ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។"បណ្ណ័សមាជិក **ប.ស.ស**" ត្រូវប្រគល់ជូនកម្មករនិយោជិត តាមរយៈនិយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន។

ក្នុងករណីដែល "បណ្ណ័សមាជិក **ប.ស.ស**" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ ៣០

[35] ការងារបញ្ជិកា,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៤ មិថុនា ២០២០)

(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ។ ការផ្តល់ប័ណ្ណទុតិយតា តម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន ២,០០០(ពីរពាន់)រៀល ជូនទៅ **ប.ស.ស**។[36]

**ឃ. របាយការណ៍កម្មករនិយោជិត**

ជារៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅ **ប.ស.ស** យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ដែលត្រូវផ្តល់ជូន **ប.ស.ស** អាចតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូនចុះហត្ថលេខាដោយនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។[37]

ចំពោះកម្មករនិយោជិតដែលទើបចូលបម្រើការងារថ្មី ហើយមិនទាន់មានលេខអត្តសញ្ញាណ **ប.ស.ស** (លេខ១៥ខ្ទង់) និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចបញ្ជូនកម្មករនិយោជិតថ្មីនេះ មកចុះបញ្ជិកានៅ **ប.ស.ស** តាមទម្រង់សលាកបត្រព័ត៌មានយ៉ាងយូររយៈពេល ០៣ថ្ងៃ បន្ទាប់ពីអនុញ្ញាតឱ្យចូលធ្វើការ ដើម្បីទទួលបានលេខអត្តសញ្ញាណ **ប.ស.ស** (លេខ១៥ខ្ទង់)។[38]

**កថាខណ្ឌទី ២ ៖ ការបង់ភាគទាន**

**ក. កាតព្វកិច្ច និងអត្រានៃការបង់ភាគទាន**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) និងមានកម្មករនិយោជិតចាប់ពី ៨ (ប្រាំបី)នាក់ឡើងទៅ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារជូនដល់បេឡាជាតិរបបសន្តិសុខសង្គម។ ភាគទានផ្នែកហានិភ័យការងារ គឺជាកាតព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។ កម្មករនិយោជិត មិនតម្រូវឱ្យមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះទេ។[39]

---

[36] ប្រកាសស្តីពីការកែសម្រួលប្រការ ៣ ប្រការ ៤ និងប្រការ ៥ នៃប្រកាសលេខ ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ២៨៥ កប/ប្រក.១៨ វិច្ឆិកា ២០១៤. ប្រការ៤ ថ្មី

[37] ប្រកាសស្តីពីការកែសម្រួលប្រការ ៣ ប្រការ ៤ និងប្រការ ៥ នៃប្រកាសលេខ ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**). លេខ២៨៥ កប/ប្រក.១៨ វិច្ឆិកា ២០១៤. ប្រការ៥ ថ្មី

[38] ការងារបញ្ជិកា,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៤ មិថុនា ២០២០)

[39] ប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ. លេខ១០៨ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ១

អត្រាភាគទានផ្នែកហានិភ័យការងារជាអត្រាឯកភាពដែលត្រូវបានកំណត់ស្មើនឹង ០.៨ (សូន្យក្បៀសប្រាំបី)ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត ដូចមានចែងក្នុង ឧបសម្ព័ន្ធ១ នៃប្រកាសស្តីពី ការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ(២០០៨) ។ ក្នុងករណីដែលសហគ្រាសគ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស អត្រានៃប្រាក់ឈ្នួលមធ្យមខាងលើត្រូវទូទាត់តាមអត្រាប្តូរប្រាក់របស់ ធនាគារជាតិនៃកម្ពុជា។

អត្រាភាគទាន ត្រូវកំណត់ជាថ្មីដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទៅតាមស្ថានភាពជាក់ស្តែងនៃបម្រែបម្រួលវិស័យឧស្សាហកម្មនៅកម្ពុជា និងទៅតាមចំណាត់ថ្នាក់ឧស្សាហកម្ម។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវបង់ភាគទានជាប្រចាំខែ។ ការគណនាប្រាក់ភាគទាន ត្រូវគិតនៅថ្ងៃចុងក្រោយនៃខែដែលត្រូវបង់នីមួយៗ។[40]

## អត្រាបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ[41]

| ថ្នាក់ | ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (គិតជារៀល) | ភាគទានប្រចាំខែសម្រាប់កម្មករនិយោជិត ១ នាក់ (0.៨%) |
|---|---|---|---|
| ១ | តិចជាង ២០០,000 | ២០០,000 | ១,៦០០ |
| ២ | ២០០,00១ - ២៥០,000 | ២២៥,000 | ១,៨០០ |
| ៣ | ២៥០,00១ - ៣០០,000 | ២៧៥,000 | ២,២០០ |
| ៤ | ៣០០,00១ - ៣៥០,000 | ៣២៥,000 | ២,៦០០ |
| ៥ | ៣៥០,00១ - ៤០០,000 | ៣៧៥,000 | ៣,000 |
| ៦ | ៤០០,00១ – ៤៥០,00១ | ៤២៥,000 | ៣,៤០០ |
| ៧ | ៤៥០,00១ – ៥០០,000 | ៤៧៥,000 | ៣,៨០០ |
| ៨ | ៥០០,00១ – ៥៥០,000 | ៥២៥,000 | ៤,២០០ |
| ៩ | ៥៥០,00១ – ៦០០,000 | ៥៧៥,000 | ៤,៦០០ |
| ១០ | ៦០០,00១ – ៦៥០,000 | ៦២៥,000 | ៥,000 |
| ១១ | ៦៥០,00 - ៧០០,000 | ៦៧៥,000 | ៥,៤០០ |

[40] ប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ. លេខ១០៨ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ២

[41] ការបង់ភាគទាន,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៤ មិថុនា ២០២០)

| | | | |
|---|---|---|---|
| ១២ | ៧០០,០០១ - ៧៥០,០០០ | ៧២៥,០០០ | ៥,៨០០ |
| ១៣ | ៧៥០,០០១ - ៨០០,០០០ | ៧៧៥,០០០ | ៦,២០០ |
| ១៤ | ៨០០,០០១ – ៨៥០,០០០ | ៨២៥,០០០ | ៦,៦០០ |
| ១៥ | ៨៥០,០០១ – ៩០០,០០០ | ៨៧៥,០០០ | ៧,០០០ |
| ១៦ | ៩០០,០០១ – ៩៥០,០០០ | ៩២៥,០០០ | ៧,៤០០ |
| ១៧ | ៩៥០,០០១ - ១.០០០,០០០ | ៩៧៥,០០០ | ៧,៨០០ |
| ១៨ | ១,០០០,០០១ - ១,០៥០,០០០ | ១,០២៥,០០០ | ៨,២០០ |
| ១៩ | ១,០៥០,០០១ - ១,១០០,០០០ | ១,០៧៥,០០០ | ៨,៦០០ |
| ២០ | ១,១០០,០០១ - ១,១៥០,០០០ | ១,១២៥,០០០ | ៩,០០០ |
| ២១ | ១,១៥០,០០១ - ១,២០០,០០០ | ១,១៧៥,០០០ | ៩,៤០០ |
| ២២ | ១,២០០,០០១ ឡើង | ១,២០០,០០០ | ៩,៦០០ |

**ខ. កាលបរិច្ឆេទនៃការបង់ភាគទាន**

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទ ដែល **ប.ស.ស** បានចេញ "វិញ្ញាបនបត្របញ្ជិកា សហគ្រាស គ្រឹះស្ថាន"។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតនៅថ្ងៃទី១៥ នៃខែបន្ទាប់។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទ ដែលបានកំណត់ ត្រូវបង់បន្ថែមនូវការប្រាក់ប្រចាំខែតាមអត្រាពីរ (២)ភាគរយ នៃចំនួនភាគទានជាក់ស្តែងដែលត្រូវបង់ក្នុងខែនីមួយៗ និងត្រូវទទួលការពិន័យជាប្រាក់ ដូចមានចែងក្នុងមាត្រា៣៦ នៃច្បាប់ស្តីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[42]

**គ. នីតិវិធី និងបែបបទបង់ភាគទាន**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីរបស់ **ប.ស.ស** ដែលស្ថិតក្នុងធនាគារ ACLEDA។ ការបង់ភាគទាន អាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម៖

- និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ
- និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈ ACLEDA Unity ឬ Internet Banking។ ការចំណាយលើសេវាកម្មនេះគឺជាបន្ទុកផ្ទាល់របស់និយោជក។

[42] ការបង់ភាគទាន,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៨ មិថុនា ២០២០)

បន្ទាប់មកនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកឯកសារដែលបានបង់ភាគទានមក **ប.ស.ស** តាមរបៀបដូចខាងក្រោម៖

- បញ្ជូនឯកសារដោយផ្ទាល់មក **ប.ស.ស** ឬសាខា **ប.ស.ស** ខេត្ត/ខណ្ឌ ឬ
- បញ្ជូនឯកសារតាមរយៈសារអេឡិចត្រូនិច contribution@nssf.gov.kh ។

ចំពោះ ឯកសារដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានភ្ជាប់មក **ប.ស.ស** មានដូចជា៖

- បញ្ជិកាកម្មករនិយោជិត (E-Form)
- តារាងបើកបៀវត្ស(Payroll list)
- លិខិតប្រកាសបង់ភាគទាន
- លិខិតបញ្ជាក់ពីនិយោជក(Form B)
- បង្កាន់ដៃបង់ប្រាក់ពីធនាគារ(Bank slip) ។

ករណីឯកសារដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន បញ្ជូនតាមរយៈអ៊ីម៉ែល(Email) ឬកម្មវិធីគេហទំព័រ(Web application) ត្រូវស្កេនឯកសារមាន លិខិតប្រកាសបង់ភាគទាន លិខិតបញ្ជាក់ពីនិយោជក និងបង្កាន់ដៃបង់ប្រាក់ពីធនាគារ និងចម្លងឯកសារទន់(Copy Soft) មានបញ្ជិកាកម្មករនិយោជិត(E-form) និង តារាងបើកបៀវត្ស (Payroll list)។

**ប.ស.ស** ពិនិត្យឃើញថាត្រឹមត្រូវហើយ នឹងចេញលិខិតបញ្ជាក់ការបង់ភាគទានជូនទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានវិញ។[43]

**ឃ. ការត្រួតពិនិត្យសៀវភៅបើកប្រាក់ និងបញ្ជីឈ្មោះកម្មករនិយោជិត**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ ( តារាងបើកប្រាក់បៀវត្សនីមួយៗ ) បញ្ជីឈ្មោះកម្មករនិយោជិត និងឯកសារពាក់ព័ន្ធផ្សេងៗ ជូន **ប.ស.ស** ដើម្បីពិនិត្យនៅពេលចាំបាច់។[44]

## ផ្នែកទី២ ៖ ការផ្តល់សេវាផ្នែកហានិភ័យការងារ

### កថាខណ្ឌទី ១ ៖ ការទទួលបានសេវាហានិភ័យការងារ

**ក. លក្ខខណ្ឌដែលចាត់ទុកជាគ្រោះថ្នាក់ការងារ**

លក្ខខណ្ឌដែលគេចាត់ទុកថាជាគ្រោះថ្នាក់ការងារមានដូចជា៖

- ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះជាហេតុយ៉ាងណាក៏ដោយ ទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករ និយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬ ម្ចាស់

---

[43] ការបង់ភាគទាន,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៨ មិថុនា ២០២០)

[44] ការបង់ភាគទាន,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី១៨ មិថុនា ២០២០)

សហគ្រាស គ្រឹះស្ថាន ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ

- ពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយ គ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ
- បណ្តាលមកពីជំងឺវិជ្ជាជីវៈ (មុខរបរប្រើកម្លាំងកាយ មុខរបរប៉ះពាល់ជាតិពុល ឬមុខរបរក្នុងលក្ខខណ្ឌមិនប្រក្រតីដែលនាំឱ្យអ្នកធ្វើការកើតជំងឺផ្សេងៗ)។[45]

**ខ. សិទ្ធិទទួលបានសេវា**

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុង **ប.ស.ស** មានសិទ្ធិទទួលបាន តាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជន ទទួលរងហានិភ័យការងារ។

មូលដ្ឋានសុខាភិបាល(មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល) ត្រូវមានការទទួលស្គាល់ពី **ប.ស.ស**។[46]

**គ. ការជូនដំណឹងហានិភ័យការងារ**




កម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនិយោជក អំពី ហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ) ដែលធ្លាក់មកលើខ្លួន។ ក្នុងករណីដែលមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះត្រូវធ្លាក់លើសិទ្ធិវន្ត នៃជនរងគ្រោះ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបប

---

[45] តាវកាលិក,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី៣០ មិថុនា ២០២០)

[46] តាវកាលិក,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី៣០ មិថុនា ២០២០)

សន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ហើយដែលបានចុះបញ្ជិកានៅក្នុង **ប.ស.ស** ត្រូវជូនដំណឹងទៅ **ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨(សែសិបប្រាំបី)ម៉ោង នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលដំណឹងអំពី ហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន។[47]

ការជូនដំណឹងអំពីហានិភ័យការងារត្រូវធ្វើតាមទម្រង់ "របាយការណ៍ហានិភ័យការងារ" ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសរួមលេខ១១០ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការជូនដំណឹងហានិ-ភ័យការងារ។[48]

ករណីគ្រោះថ្នាក់ការងារ ត្រូវផ្ញើរបាយការណ៍ហានិភ័យការងារ ដោយភ្ជាប់មកជាមួយនឹងឯកសារពាក់ព័ន្ធតាមរយៈសារអេឡិចត្រូនិច benefit@nssf.gov.kh។[49]

**ឃ. ការអង្កេតហានិភ័យការងារ**

បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម។ អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានយ៉ាងឆាប់បំផុត។[50]

ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។[51]

ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ។[52]

[47] ប្រកាសរួមស្តីពីការជូនដំណឹងហានិភ័យការងារ. លេខ១១០ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ១

[48] ប្រកាសរួមស្តីពីការជូនដំណឹងហានិភ័យការងារ. លេខ១១០ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ២

[49] តាវកាលិក,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី៣០ មិថុនា ២០២០)

[50] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ៣.១

[51] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ៣.២

[52] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ៣.៣

## កថាខណ្ឌទី២ ៖ តាវកាលិកហានិភ័យការងារ

### ក. ការផ្តល់សេវាសង្គ្រោះបន្ទាន់

សេវាសង្គ្រោះបន្ទាន់ គឺជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ។[53]

ក្នុងករណីគ្រោះថ្នាក់កើតឡើងនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពី **ប.ស.ស**។[54]

### ខ. ការផ្តល់សេវាថែទាំ និងព្យាបាល

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាលការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គមផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី។ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសម្ភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងក្នុងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅ ជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ។[55]

### គ. តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវកំណត់ដូចតទៅ៖

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកព្យាបាលក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា។

ក្នុងរយៈពេលនៃការបាត់បង់សមត្ថមភាពការងារបណ្តោះអាសន្ន ដូចបានចែងខាងលើកម្មករនិយោជិតដែលរងគ្រោះដោយហានិភ័យការងារ មានសិទ្ធិទទួលបានតាវកាលិក **ប.ស.ស** ដូចតទៅ៖

---

[53] ផ្អែកថែទាំសុខភាព,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី៣០ មិថុនា ២០២០)

[54] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ៤

[55] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ៥

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំជនរងគ្រោះក្នុងរយៈពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុ-ព្យាបាល។

ប្រាក់ឈ្នួលនៃថ្ងៃផ្អាកការងារដំបូងរបស់ជនរងគ្រោះថ្នាក់ការងារ ត្រូវនៅក្នុងបន្ទុករបស់និយោជក។ ប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវស្មើនឹង ៧០(ចិតសិប)ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលត្រូវស្មើនឹង ៥០ (ហាសិប)ភាគរយ នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ។[56]

**ឃ. តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារ ជាអចិន្ត្រៃយ៍តិចជាង២០ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍ សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនអ្នករងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

**វបក = បឈម × កបក × ២០% មតប**

- **វបក** : វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម** : ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក** : កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មតប** : មេគុណតម្លៃបច្ចុប្បន្ន

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូមមន្តដូចដែលមានខាងក្រោម៖

**ធល = បឈម × [ កបក – ១/៥ កបក ]**

- **ធល** : ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញ

[56] ប្រកាសស្តីពីការកែសម្រួលប្រការ ៧ និងប្រការ ៩ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ. លេខ១៤០ កប/ប្រក.១៥ មិថុនា ២០១០. ប្រការ៧ ថ្មី

ក្នុងរយៈពេល ១ (មួយ)ឆ្នាំយ៉ាងយូរ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។[57]

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ដែលតម្រូវឱ្យមានអ្នកចាំថែរទាំរក្សា មានសិទ្ធិទទួលបានការឧបត្ថម្ភបន្ថែមស្មើនឹង ៥០ (ហាសិប)ភាគរយ នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។ សិទ្ធិទទួលបានអ្នកចាំថែរក្សា ត្រូវសម្រេចដោយនាយក **ប.ស.ស** អនុលោមទៅតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ។[58]

**ខ. វិភាជន៍ជាសោហ៊ុយបូជាសព**

សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក **ប.ស.ស** ដែលទទួលមរណភាព។[59]

ក្នុងករណីដែលទទួលរងហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ៤,០០០,០០០ (បួនលាន) រៀល។ ប្រាក់វិភាជន៍នេះត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។[60]

**ច. តាវកាលិកឧត្តរជីវី**

ឧត្តមជីវី សំដៅដល់បុគ្គលដែលរស់នៅក្នុងបន្ទុកផ្ទាល់នៃសមាជិក **ប.ស.ស** មុនកាលបរិច្ឆេទដែលសាមីជនបានទទួលមរណភាព។[61]

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ។ តាមអត្រាដូចខាងក្រោម[62]៖

- ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក
  - ប្រពន្ធ ឬប្តី = ៣/៥ × ៦៣% បឈម
  - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៦៣% បឈម

---

[57] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ. លេខ២៣៣ កប/ប្រក.០៧ វិច្ឆិកា ២០១១. ប្រការ៧៨ ថ្មី

[58] តាវកាលិក,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី៥ កក្កដា ២០២០)

[59] និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម នៃច្បាបស្តីពីរបបសន្តិសុខសង្គមលេខ៣៣៤ នស/រកម. ២ វិច្ឆិកា ២០១៩.

[60] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ. លេខ២៣៣ កប/ប្រក.០៧ វិច្ឆិកា ២០១១. ប្រការ៧១០ ថ្មី

[61] និយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម នៃច្បាបស្តីពីរបបសន្តិសុខសង្គមលេខ៣៣៤ នស/រកម. ២ វិច្ឆិកា ២០១៩.

[62] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ១១.២

– ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

▪ ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និង/ឬ កូន

– ប្រពន្ធ ឬប្តី = ៣/៥ × ៧០% បឈម

– ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៧០% បឈម

▪ ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

– ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

▪ ក្នុងករណីសិទ្ធិវន្តមានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

– ធនលាភសរុបសម្រាប់ក្នុងបន្ទុក = ២៨% បឈម

– ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

▪ ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

– ប្រពន្ធ ឬប្តី = ២៨% បឈម

– ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

លក្ខខណ្ឌដែលត្រូវទទួលបាន " តាវកាលិកឧត្តរជីវី " សិទ្ធិវន្តរបស់សមាជិកនៃ **ប.ស.ស** ត្រូវបានកំណត់ដូចខាងក្រោម៖

▪ ប្តី ឬប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ដោយបានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារ រវាងប្តីឬប្រពន្ធ ដែលជាសមាជិកនៃ **ប.ស.ស**

▪ កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី)ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាពដូចខាងក្រោម៖

– កូននៃសហព័ទ្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយ ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទីមួយដែរ

– កូនចិញ្ចឹមរបស់សមាជិកនៃ **ប.ស.ស**។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន

– អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១(ម្ភៃមួយ)ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនកំពុងរៀននៅក្នុងគ្រឹះស្ថាន សិក្សាសាធារណៈ ឬឯកជនដែលមានការទទួល

ស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល

- ឪពុកម្តាយ ឬមនុស្សចាស់ជរា ដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃ **ប.ស.ស**
- សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព ឬរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមក **ប.ស.ស** យ៉ាងយូរ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខក ខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[63]

**ឆ. សេវាបុនរ្នីតិសម្បទា**

កម្មករនិយោជិតដែលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិត តាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ កម្មករនិយោជិត ដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[64]

[63] តាវកាលិក,អាចរកបាននៅ http://www.nssf.gov.kh (ចូលទស្សនា ថ្ងៃទី២៧ កក្កដា ២០២០)

[64] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ. លេខ១០៩ កប/ប្រក. ១៦ មិថុនា ២០០៨. ប្រការ១២

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ផ្នែកទី ១ ៖ បញ្ហាប្រឈម

### កថាខណ្ឌទី ១ ៖ ចំពោះនិយោជក សហគ្រាស គ្រឹះស្ថាន និងនិយោជិត

**ក. និយោជក សហគ្រាស គ្រឹះស្ថានមួយចំនួន**

- ចំពោះសហគ្រាសប្រភេទ ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ ដែលភាគច្រើនធ្វើអាជីវកម្មពេលយប់ ពិបាកណាត់ជួបម្ចាស់ ឬអ្នកតំណាង ដើម្បីពន្យល់អំពីការអនុវត្តរបបសន្តិសុខសង្គម
- ចំពោះសហគ្រាសវិស័យសំណង់ ឡូតដ្ឋ ដែលមានចលនាបុគ្គលិកញឹកញាប់ ពិបាកក្នុងការចុះបញ្ជិកាកម្មករនិយោជិត
- បិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរម្ចាស់ ប្តូរយីហោថ្មី ដោយមិនបានជូនដំណឹងមក **ប.ស.ស**
- ប្រភេទសិប្បកម្មមិនរៀបរយ គ្មានឯកសារគតិយុត្តត្រឹមត្រូវ
- ផ្តល់ឯកសារទាមទារតាវកាលិកហានិភ័យការងារមិនត្រឹមត្រូវ យឺតយ៉ាវ
- សហគ្រាស គ្រឹះស្ថាន មួយចំនួនបង់ភាគទានមិនត្រឹមត្រូវ ឬយឺតយូរ និងរាយការណ៍ចំនួនកម្មករនិយោជិតមិនគ្រប់ចំនួន
- មិនទាន់ស្គាល់ **ប.ស.ស** ច្បាស់ពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជិកា បង់ភាគទាន និងផ្តលទិន្នន័យកម្មករនិយោជិតមិនច្បាស់តាមខែនីមួយៗ
- ពន្យាពេលក្នុងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត
- ផ្តល់របាយការណ៍ហានិភ័យការងារមិនត្រឹមត្រូវ យឺតយ៉ាវ រក្សាទុកឯកសារទាមទារតាវកាលិកយូរ ឬចាំសរុបរួមទើបផ្ញើមក **ប.ស.ស**។[65]

**ខ. និយោជិត**

- មិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណច្បាស់លាស់ ជាពិសេសកម្មករនិយោជិតនៅក្នុងសហគ្រាសតូចៗ មិនរៀបរយ
- កម្មករនិយោជិតមួយចំនួនតូច មិនមានសំបុត្រអាពាហ៍ពិពាហ៍

[65] របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

- កម្មករចំណាកស្រុកមួយចំនួន (ចំការកៅស៊ូ ឡឥដ្ឋ សំណង់...) គ្មានឯកសារកំណត់បញ្ជាក់អត្តសញ្ញាណ
- កម្មករនិយោជិតមួយចំនួនតូចនៅបន្តៈ
  - ខ្ចីឯកសារគេប្រើ មិនហ៊ានប្រាប់ខ្លាចគេបញ្ឈប់ការងារ
  - ខ្លាចបាត់អតីតភាពការងារ ពេលប្តូរឈ្មោះត្រឹមត្រូវវិញ
- លិខិតបទដ្ឋានសម្រាប់អនុវត្តរបបសន្តិសុខសង្គមផ្នែកសោធន នៅមិនទាន់រៀបចំបានចប់សព្វគ្រប់
- មិនទាន់យល់ច្បាស់ពី **ប.ស.ស** មិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណច្បាស់ និងទាមទារតាវកាលិក មិនមែនគ្រោះថ្នាក់ការងារ
- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** និងប្រើប្រាស់សេវាមិនចំគោលដៅ។[66]

**កថាខណ្ឌទី ២ ៖ ចំពោះសេវាសុខាភិបាល**

សេវាសុខាភិបាលមួយចំនួនតូចៈ

- គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ របស់មន្ទីរពេទ្យមូលដ្ឋាន នៅមានកម្រិត
- ខ្វះការសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម
- ឥរិយាបថនៃការផ្តល់សេវាព្យាបាល ជូនចំពោះកម្មករនិយោជិតនៅមានកម្រិតនៅឡើយ
- ការផ្តល់សេវាមិនបានគោរពទៅតាមគោលការណ៍របស់ក្រសួងសុខាភិបាល និងកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**
- បង្កើតតម្លៃសេវាបន្ថែមក្រៅគោលការណ៍ពីការកំណត់។

**កថាខណ្ឌទី ៣ ៖ ចំពោះបេឡាជាតិរបបសន្តិសុខសង្គម**

- កង្វះធនធានមនុស្ស
- ទីស្នាក់ការកណ្តាលរបស់ **ប.ស.ស** នៅមានសភាពតូចចង្អៀតនៅឡើយ
- ខ្វះការយកចិត្តទុកដាក់ក្នុងការឆ្លើយតបតាមរយៈលេខទំនាក់ទំនងដែលបានបង្ហាញនៅលើគេហទំព័រផ្លូវការរបស់ខ្លួន។

[66] របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## ផ្នែកទី ២ ៖ ដំណោះស្រាយ

### កថាខណ្ឌទី ១ ៖ ចំពោះនិយោជក សហគ្រាស គ្រឹះស្ថាន និងនិយោជិត

ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យមានប្រសិទ្ធភាព ទាន់ពេលវេលា និងដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាបេឡាជាតិរបបសន្តិសុខសង្គម មានទិសដៅសំខាន់ៗមួយចំនួនសម្រាប់អនុវត្តបន្តដូចខាងក្រោម៖

**ក. និយោជក សហគ្រាស គ្រឹះស្ថានមួយចំនួន**

- ផ្សព្វផ្សាយនិងពន្យល់ណែនាំពីយន្តការអនុវត្តជាធរមាន និងចាត់វិធានការតាមច្បាប់ចំពោះ សហគ្រាសប្រភេទ ភោជនីដ្ឋាន ក្លឹមកំសាន្ត ខារ៉ាអូខេ
- រៀបចំនីតិវិធីចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត វិស័យសំណង់ ឡូតដូ ដែលមានចលនាបុគ្គលិកញឹកញាប់
- រៀបចំយន្តការ នៃការជូនដំណឹង ចំពោះសហគ្រាស គ្រឹះស្ថាន បិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរម្ចាស់ ប្តូរយីហោថ្មី
- សហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរដែនដី ដើម្បីកំណត់អត្តសញ្ញាណសិប្បកម្មមិនរៀបរយ គ្មានឯកសារគតិយុត្តត្រឹមត្រូវ
- កែសម្រួលនីតិវិធិ នៃការជូនដំណឹងហានិភ័យការងារ
- ពង្រឹងការចុះអធិការកិច្ច ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបង់ភាគទានមិនត្រឹមត្រូវ ឬយឺតយូរ និងរាយការណ៍ចំនួនកម្មករនិយោជិតមិនគ្រប់ចំនួន
- បន្តផ្សព្វផ្សាយពន្យល់ណែនាំពីយន្តការអនុវត្តជាធរមាន
- បន្តព្យាយាមសម្របសម្រួលណាត់ជួបនៅពេលរសៀល និងពន្យល់ឱ្យអស់លទ្ធភាពមុននឹងចាត់វិធានការ
- ព្យាយាមទំនាក់ទំនងផ្ទាល់ ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារបង់ភាគទាន និងឯកសារទាមទារតាវកាលិក
- ចុះទៅទារផ្ទាល់តាមរយៈការដាក់លិខិតកំហិត។[67]

**ខ. និយោជិត**

- បន្តផ្សព្វផ្សាយ និងសហការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដល់កម្មករនិយោជិតនៅក្នុងសហគ្រាសតូចៗមិនរៀបរយ

[67] របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

- ផ្សព្វផ្សាយសារៈសំខាន់នៃសំបុត្រអាពាហ៍ពិពាហ៍ ដល់កម្មករនិយោជិត
- ផ្សព្វផ្សាយដល់កម្មករចំណាកស្រុក ដែលធ្វើការនៅ ចម្ការកៅស៊ូ ឡូតដូ សំណង់... គ្មានឯកសារកំណត់បញ្ជាក់អត្តសញ្ញាណ ឱ្យបានយល់ដឹងពីអត្ថប្រយោជន៍នៃឯកសារ
- ផ្សព្វផ្សាយដល់កម្មករនិយោជិតអំពីផលវិបាកនៃការខ្ចីឯកសារអ្នកដទៃ ឬការភ័យខ្លាច ក្នុងការបាត់បង់អតីតភាពការងារ
- ណែនាំឱ្យទៅយកសេវាជាមួយមូលដ្ឋានសុខាភិបាល ដែលចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** វិញ។
- ចុះសម្របសម្រួល និងពន្យល់ផ្ទាល់ពីគោលការណ៍ជាធរមាន។[68]

**កថាខណ្ឌទី ២ ៖ ចំពោះសេវាសុខាភិបាល**

- សម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង និងប្រជុំដោះស្រាយបញ្ហានានាដែលធ្លាប់បានកើតមានឡើងកន្លងមក ដើម្បីអនុវត្តការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពជូនកម្មករនិយោជិត
- ជំរុញ និងលើកទឹកចិត្តបណ្តាមូលដ្ឋានសុខាភិបាលនានា ឱ្យសហការ និងចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**
- បញ្ជូនភ្នាក់ងារ **ប.ស.ស** ទៅតាមបណ្តាមូលដ្ឋានសុខាភិបាលនីមួយៗ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**។

**កថាខណ្ឌទី ៣ ៖ ចំពោះបេឡាជាតិរបបសន្តិសុខសង្គម**

- រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសិលាទាក់ទងនឹងចំណេះដឹងផ្នែកហានិភ័យការងារឱ្យបានច្រើន
- ចែករំលែក និងផ្សព្វផ្សាយព័ត៌មាននានា ដែលទាក់ទងនឹងផ្នែកហានិភ័យការងារតាមរយៈមធ្យោបាយផ្សេងៗ ដូចជាការចុះផ្សព្វផ្សាយដោយផ្ទាល់ ឬក៏តាមរយៈបណ្តាញសង្គមជាដើម
- សាងសង់អគារបន្ថែមដើម្បីសម្រួលដល់ការធ្វើការងាររបស់មន្ត្រីដែលបម្រើការងារនៅ **ប.ស.ស** ក្នុងការផ្តល់សេវាជូនសមាជិករបស់ខ្លួន
- បង្កើនការយកចិត្តទុកដាក់ក្នុងការឆ្លើយតបតាមរយៈបណ្តាញទំនាក់ទំនងនានា ដែលខ្លួនមាន ឬគួរតែមានមន្ត្រីណាម្នាក់ប្រចាំការ ដើម្បីធ្វើការឆ្លើយតប។

[68] របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## ផ្នែកទី ៣ ៖ ទស្សនភាពនៃការផ្តល់សេវារបស់បេឡាជាតិរបបសន្តិសុខសង្គម

### កថាខណ្ឌទី ១ ៖ កំណែទម្រង់

**ក. ការងារព័ត៌មានវិទ្យា**

**ប.ស.ស** បានរៀបចំកិច្ចប្រតិបត្តិការ និងគ្រប់គ្រងទិន្នន័យតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាលើការងារចុះបញ្ជិកា បង់ភាគទាន ការផ្តល់តាវកាលិក ការគ្រប់គ្រងវត្តមានមន្ត្រី និងការងារសំខាន់ៗមួយចំនួនទៀត ជាក់ស្តែងក្នុងឆ្នាំ២០១៩ **ប.ស.ស** សម្រេចបានលើការងារព័ត៌មានវិទ្យារួមមាន ការងារបច្ចុប្បន្នភាពកម្មវិធីឱ្យកាន់តែប្រសើរឡើង និងការងារបង្កើតកម្មវិធីសម្រាប់បំពេញការងារជាដើម។

**ខ. ការងារសវនកម្មផ្ទៃក្នុង**

ពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង តាមរយៈការចុះធ្វើសនវកម្មនៅតាមបណ្តាការិយាល័យជំនាញទីស្នាក់ការកណ្តាល និងការិយាល័យសាខាខេត្ត/ខណ្ឌ។

### កថាខណ្ឌទី ២ ៖ សមិទ្ធផល

នៅក្នុងឆ្នាំ២០១៩នេះ **ប.ស.ស** សម្រេចបានសមិទ្ធផលដូចជា៖

- បានចុះបញ្ជិកាសមាជិកផ្នែកហានិភ័យការងារសរុបចំនួន ៨០,៧៨៥នាក់ និងសហគ្រាសចំនួន ២,១៦៣ ដែលក្នុងនោះ រាជធានីភ្នំពេញ មានចំនួន ៤១,៤៣៧នាក់ និង ១,២៦៧ សហគ្រាស
- ប្រសិទ្ធិភាពនៃការបង់ភាគទានពីបណ្តាសហគ្រាស គ្រឹះស្ថានមានរហូតដល់ ៩១.២៣%
- លទ្ធផលអង្កេតហានិភ័យការងារមានចំនួនសរុប ២០,១៥៨ ករណី ដែលក្នុងនោះនៅរាជធានីភ្នំពេញមានចំនួន ៧,៥៥៥ករណី
- ការចុះកិច្ចព្រមព្រៀងជាមួយ មូលដ្ឋានសុខាភិបាលបានផ្នែកហានិភ័យការងារមានចំនួន ២៣៣កន្លែង ដែលក្នុងនោះរាជធានីភ្នំពេញមានចំនួន ៥៥កន្លែង
- ការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារបានចំនួន ៣៧លើក
- ការផ្សព្វផ្សាយអប់រំអំពី លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍ការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម និងសុវត្ថិភាពចរាចរណ៍ក្នុងការធ្វើដំណើររបស់កម្មករនិយោជិត បានចំនួន ៣៤លើក
- ការផ្តល់តាវកាលិកហានិភ័យការងារសរុបមានចំនួន ១៦,៥១១ករណី។ល។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជារួមមកបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **ការផ្តល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩** រួចមក យើងឃើញថា **ប.ស.ស** ទើបតែដាក់ឱ្យដំណើរការជាផ្លូវការក្នុងឆ្នាំ២០០៨ នេះតែប៉ុណ្ណោះ ដើម្បីអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង ដោយធានាឱ្យបាននូវសន្តិសុខសង្គមប្រកបដោយសមធម៌ សាមគ្គីធម៌សង្គម លើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ។ **ប.ស.ស** បង្កើតឡើងដំបូងអនុវត្តត្រឹមតែការផ្តល់សេវាផ្នែកហានិភ័យការងារ លុះក្រោយមកទៀតទើបឈានទៅដល់ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន។

**ប.ស.ស** គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជានីតិបុគ្គលសាធារណៈ មានស្វ័យភាពខាងហិរញ្ញវត្ថុ ដែលមានបេសកកម្ម បម្រើសេវាផ្នែកសាធារណៈរដ្ឋបាលមានលក្ខណៈសង្គម ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ **ប.ស.ស** ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថាន ក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ចំណែកឯ ភារកិច្ចចាត់ចែង គ្រប់គ្រង និងការងារប្រចាំថ្ងៃត្រូវបានដឹកនាំដោយនាយកនៃ **ប.ស.ស**។

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ដែលជាជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តតាំងពីខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ននេះ បាននិងកំពុងចូលរួមចំណែកលើកកម្ពស់សុវត្ថិភាព និងសុខភាពនៅកន្លែងការងាររបស់កម្មករនិយោជិតជាច្រើន ដើម្បីបង្ការកុំឱ្យនិយោជិតទាំងអស់ធ្លាក់ទៅក្នុងភាពក្រីក្រ។ កម្មករនិយោជិតនៃ សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅ **ប.ស.ស** ទាំងអស់សុទ្ធតែមានសិទ្ធិក្នុងការទទួលបានតាវកាលិកហានិភ័យ នៅពេលដែលសាមីជនទទួលរងហានិភ័យការងារ។ ចំណែកឯលក្ខខណ្ឌដើម្បីទទួលបានតាវកាលិក លុះត្រាតែគ្រោះថ្នាក់ទាំងនោះបណ្តាលមកពីហានិភ័យការងារ ដែលតម្រូវឱ្យមានការអង្កេត និងវាយតម្លៃពីអធិការ ឬអភិបាលសន្តិសុខសង្គម។

ជាក់ស្តែងបើយោងតាម របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត បានឆ្លុះបញ្ចាំងឱ្យឃើញថា ការផ្តល់សេវាផ្នែកហានិភ័យការងារទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ តាមរយៈការធ្វើកំណែទម្រង់មួយចំនួនដូចជា ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានលើការងារចុះបញ្ជិកា បង់ភាគទានការផ្តល់តាវកាលិក ការគ្រប់គ្រងវត្តមានមន្ត្រី និងការងារសំខាន់ៗមួយចំនួនទៀត គួបផ្សំនឹងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិករបស់ **ប.ស.ស** និងមានការសហការពីបណ្តាដៃគូពាក់ព័ន្ធនានា។

ទន្ទឹមនឹងសមិទ្ធផលទាំងនេះ **ប.ស.ស** នៅតែជួបបញ្ហាមួយចំនួនទៀតដូចជា ការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់ និយោជក និងនិយោជិតមួយចំនួនតូច គុណភាព និងឥរិយាបថ នៃកាផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ ព្រមជាមួយបញ្ហារបស់ **ប.ស.ស** មួយចំនួនផងដែរ។ ដូចនេះដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមទាំងនេះ វាទាមទារឱ្យមានការចូលរួមសហការបន្ថែមទៀត ពីសំណាក់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង ជាពិសេស ការជួយជំរុញផ្សព្វផ្សាយអប់រំ ក្នុងគោលបំណង បង្ការ និងទប់ស្កាត់គ្រោះថ្នាក់ការងារឱ្យស្ថិតនៅក្នុងកម្រិតមួយទាបបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **ការផ្តល់សេវាផ្នែកហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គមនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩** រួចមក យើងខ្ញុំទាំងពីរនាក់សង្កេតឃើញថា ការផ្តល់សេវាផ្នែកហានិភ័យការងារ ទទួលបានលទ្ធផលផ្លែផ្កាគួរឱ្យកត់សម្គាល់ និងបានអភិវឌ្ឍខ្លួនកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត។ ទន្ទឹមនឹងសមិទ្ធផលទាំងនេះ ក្រុមយើងខ្ញុំ ក៏បានមើលឃើញពីបញ្ហាប្រឈម និងចំណុចអវិជ្ជមានមួយចំនួនផងដែរ។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះក្រុមយើងខ្ញុំសុំចូលខ្លួនផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

## ១. ចំពោះបេឡាជាតិរបបសន្តិសុខសង្គម

- ធានាឱ្យបាននូវការផ្តល់តាវកាលិកប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព
- បង្កើតឱ្យមានវគ្គបណ្តុះបណ្តាជំនាញនានាដល់ មន្ត្រីគ្រប់ផ្នែក ដើម្បីពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីឱ្យកាន់ល្អប្រសើរឡើង
- ជំរុញការអភិវឌ្ឍ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ត្រី ដើម្បីពន្លឿនការបំពេញការងារ និងផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធិភាព
- បង្កើនការសហការ និងចុះកិច្ចព្រមព្រៀងបន្ថែមទៀតជាមួយបណ្តាមូលដ្ឋានសុខាភិបាល ទាំងរដ្ឋ និងឯកជន ដើម្បីឆ្លើយតបទៅនឹងតម្រូវកាជាក់ស្តែងរនាពេលបច្ចុប្បន្ន
- សហការ ជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង
- ត្រូវធ្វើការពង្រីក ឬសាងសង់អគាររដ្ឋបាលបន្ថែមទៀត ដើម្បីជួយសម្រួលដល់ការបំពេញការងាររបស់មន្ត្រី **ប.ស.ស** និងបង្កភាពងាយស្រួលដល់សមាជិក **ប.ស.ស** ទាំងអស់ក្នុងការទទួលយកសេវា
- ជំរុញការផ្សព្វផ្សាយអប់រំ ក្នុងគោលបំណង បង្ការ ទប់ស្កាត់គ្រោះថ្នាក់ការងារឱ្យស្ថិតនៅក្នុងកម្រិតមួយទាបបំផុត
- ជំរុញការយល់ដឹងជាសាធារណៈ អំពី **ប.ស.ស** ជាពិសេសចំពោះកម្មករនិយោជិត
- បង្កើនការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ផ្សេងៗដែលទទួលបាន ក្រោយក្លាយជាសមាជិក ឬដៃគូសហការជាមួយ **ប.ស.ស** តាមរយៈមធ្យោបាយនានា ដូចជា ការរៀបចំសិក្ខាសិលា ការចុះផ្សព្វផ្សាយតាមមូលដ្ឋាន ឬក៏តាមរយៈបណ្តាញសង្គមនានា។

**២. ចំពោះបណ្ដាមន្ទីរពេទ្យនានា**

- **មន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀង៖** ត្រូវខិតខំប្រឹងប្រែងក្នុងការផ្ដល់សេវាប្រកបដោយគុណភាព និងរួសរាយរាក់ទាក់ ជាពិសេសគោរពទៅតាមគោលការណ៍ដែលបានកំណត់ដោយក្រសួងសុខាភិបាល និងកិច្ចព្រមព្រៀង ជាមួយ **ប.ស.ស**។
- **មន្ទីរពេទ្យដែលមិនទាន់បានចុះកិច្ចព្រមព្រៀង៖** គួរតែធ្វើការសហការ ចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** ដើម្បីចូលរួមចំណែកក្នុងការធានាសន្តិសុខសង្គមប្រកបដោយសមធម៌ សាមគ្គីធំមសង្គម លើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ។

**៣. ចំពោះនិយោជក**

- ត្រូវផ្ដល់របាយការណ៍ចំនួនកម្មករនិយោជិតដែលពិតប្រាកដ និងបញ្ជូនកម្មករនិយោជិតទាំអស់ទៅចុះបញ្ជិកានៅ **ប.ស.ស** ព្រមទាំងបង់ភាគទានទៅតាមការកំណត់របស់ **ប.ស.ស** និងទាន់ពេលវេលា
- ជូនដំណឹងទៅ **ប.ស.ស** ចំពោះកម្មករនិយោជិតទើបតែចូលថ្មី ផ្លាស់ប្ដូរកន្លែងការងារ ឬលាឈប់ពីការងារ
- ត្រូវផ្ដល់ព័ត៌មាន ឬជូនដំណឹងទៅ **ប.ស.ស** ក្នុងករណីដែលសហគ្រាសរបស់ខ្លួន បិទទ្វារ ផ្អាកសកម្មភាព ប្ដូរអាសយដ្ឋាន ប្ដូររដ្ឋបាលថ្មី ប្ដូរម្ចាស់ ឬប្ដូរឃីហោថ្មី
- ផ្ដល់របាយការណ៍ ហានិភ័យការងារឱ្យបានច្បាស់លាស់ ដើម្បីបង្កភាពងាយស្រួលដល់មន្ត្រីរបស់ **ប.ស.ស** ក្នុងការចុះអង្កេតហានិភ័យការងារ
- ផ្ដល់ឯកសារទាមទារតាវកាលិកហានិភ័យការងារដែលត្រឹមត្រូវ និងទាន់ពេលវេលាតាមការកំណត់
- អនុវត្តកាតព្វកិច្ច និងសកម្មក្នុងការសហការជាមួយ **ប.ស.ស** ។

**៤. ចំពោះកម្មករនិយោជិត**

- ត្រូវស្វែងយល់បន្ថែមទាក់ទងទៅនឹងការលក្ខខណ្ឌផ្សេងៗដើម្បីទទួលបានតាវកាលិកហានិភ័យការងារ
- ត្រូវមានឯកសារគតិយុត្តនានា ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ និងផ្ដល់តាវកាលិកជាពិសេសចំពោះកម្មករនិយោជិតនៅក្នុងសហគ្រាសតូចៗ មិនរៀបរយ
- ចំពោះអ្នកដែលមានសហព័ទ្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍ដើម្បីងាយស្រួលក្នុងការផ្ដល់តាវកាលិកផ្នែកឧត្តមជីវី
- ត្រូវទៅព្យាបាលនៅមន្ទីរពេទ្យណាដែលបាន ចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស** និងប្រើសេវាព្យាបាលផ្នែកវេជ្ជសាស្ត្រឱ្យចំគោលដៅ ស្របទៅតាមកិច្ចព្រមរវាង **ប.ស.ស** និងមន្ទីរពេទ្យនានា។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីច្បាប់របបសន្តិសុខសង្គម
- ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- អនុក្រឹត្យលេខ១៦ អនក្រ/ប្រក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- ប្រកាសរួមលេខ១១០ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការជូនដំណឹងហានិភ័យការងារ
- ប្រកាសលេខ០២១-០៨ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**)
- សេចក្តីប្រកាសព័ត៌មាន លេខពិសេសចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**) ជូនកម្មករនិយោជិត
- ប្រកាសលេខ៤៧៧/១៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីសេវាស្តារនីតិ-សម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ៤៤៩/១៧ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនិតិវិធីនៃការបង់ភាគទាន សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ៤៤៨/១៧ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព

- ប្រកាសលេខ៤៨០/១៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ២៣៣ កប/ប្រក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ១៤០ កប/ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ២៨៥ កប/ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស**)
- ប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ
- ប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- សេចក្តីណែនាំស្តីពី នីតិវិធី និងបែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម
- សេចក្តីណែនាំស្តីពីការប្រើប្រាស់សារអេឡិចត្រូនិច **ប.ស.ស**។

## ២. **របាយការណ៍**

- របាយការណ៍ ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**)
- របាយការណ៍ ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**)។

## ៣. **គេហទំព័រ**

- គេហទំព័រផ្លូវការ របស់បេឡាជាតិរបបសន្តិសុខសង្គម http://www.nssf.gov.kh/default/
- គណនីហ្វេសប៊ុក(Facebook) ផ្លូវការរបស់ បេឡាជាតិសន្តិសុខសង្គម
- គណនីយូធូប(YouTube) ផ្លូវការរបស់ បេឡាជាតិសន្តិសុខសង្គម

- YouTube: តើបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) ជាអ្វី? បកស្រាយដោយលោក សុក ប៉ូរ៉ា ប្រធានការិយាល័យតាវកាលិក ដែលបានផ្សព្វផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ដោយគណនីឈ្មោះ Sokhakrom, (ចូលទស្សនាថ្ងៃទី៥ ខែមេសា ២០២០)
- YouTube: ការចុះបញ្ជិការសហគ្រាស និងកម្មករនិយោជិតជាមួយ **ប.ស.ស** ដែលបានផ្សព្វផ្សាយនៅថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៩ ដោយគណនីឈ្មោះ បេឡាជាតិសន្តិសុខសង្គម, (ចូលទស្សនាថ្ងៃទី២០ ខែមេសា ២០២០)
- YouTube: បទយកការណ៍៖ អ្នកប្រើប័ណ្ណ **ប.ស.ស** ត្អូញត្អែរពីការមិនយកចិត្តទុកដាក់របស់មន្ទីរពេទ្យ ដែលបានផ្សព្វផ្សាយនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ដោយគណនីឈ្មោះ VOD, (ចូលទស្សនាថ្ងៃទី២៥ ខែមេសា ២០២០) ។

# ឧបសម្ព័ន្ធទី ១

# ច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីការងារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

## របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
## ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

# LAW

## ON

## SOCIAL SECURITY SCHEMES FOR PERSONS
## DEFINED BY THE PROVISIONS OF THE LABOUR LAW

# មាតិការឿង


ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ............................ ២

ជំពូកទី ២ ផ្នែកប្រាក់សោធន ............................ ៥

ជំពូកទី ៣ ផ្នែកហានិភ័យការងារ .................... ៧

ជំពូកទី ៤ បទប្បញ្ញត្តិផ្សេងៗ ........................ ១៣

ជំពូកទី ៥ ទោសប្បញ្ញត្តិ .................................. ១៦

ជំពូកទី ៦ អវសានប្បញ្ញត្តិ ............................ ១៩

# ព្រះរាជក្រម

នស/ រកម/ ០៩០២ / ០១៨ **យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករនរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយ

គ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ ។

ច្បាប់នេះ មានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១**.-

ច្បាប់នេះមានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចតទៅ ៖

១-ផ្នែកប្រាក់សោធន ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិក ជរាភាព ទុព្វលភាព និងមរណភាព ។

២-ផ្នែកហានិភ័យការងារ ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិក គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ។

ចំពោះផ្នែកដទៃផ្សេងទៀត នឹងត្រូវកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ ។

**មាត្រា ២**.-

សេវាដែលត្រូវបំពេញបន្ថែមលើតាវកាលិកទាំងនេះ រួមមានសកម្មភាពផ្នែកសុខាភិបាល និងសង្គមកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣**.-

របបសន្តិសុខសង្គម ដែលបង្កើតដោយច្បាប់នេះត្រូវធានារ៉ាប់រងដោយបេឡាជាតិរបបសន្តិសុខសង្គម សរសេរកាត់ថា "**ប.ស.ស**" ។ បេឡាជាតិរបបសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈ ដែលត្រូវបង្កើតដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើ

ដោយព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៦ និងព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈ ។

**មាត្រា ៤**.-

ជនដែលត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គម តាមច្បាប់នេះ ដោយមិនមានបែងចែកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិ-កំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីព កម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីព គឺ ៖

-កម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ប្រសិនបើជនទាំងនោះធ្វើសកម្មភាពការងារនៅក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់និយោជកម្នាក់ ឬច្រើននាក់ដោយមិនគិតដល់ប្រភេទ ទម្រង់និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទ និងចំនួននៃប្រាក់ឈ្នួលដែលជននោះបានធ្វើ ឬបានទទួលឡើយ ។

-កម្មករនិយោជិតរដ្ឋ កម្មករនិយោជិត នៃអង្គការសាធារណៈ និងបុគ្គលិកទាំងអស់ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈទូត ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈ ដែលតែងតាំងដោយបណ្តោះអាសន្ន ។

-សិស្សសាលាវិជ្ជាជីវៈ ជនដែលដាក់ឱ្យធ្វើការងារនៅក្នុងមណ្ឌលបណ្តុះបណ្តាល សម្របសម្រួល និងអប់រំវិជ្ជាជីវៈសាឡើងវិញ និងកូនជាងត្រូវចាត់ទុកដូចជាកម្មករនិយោជិត ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះដែរ ។ បែបបទសម្រាប់អនុវត្តបទប្បញ្ញត្តិផ្នែកនេះ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

-ជនដែលប្រកបមុខរបរក្នុងវិជ្ជាជីវៈសេរី ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

-កម្មករនិយោជិតធ្វើការម្តងម្កាល ឬ តាមរដូវ ។ បែបបទចាំបាច់

ដោយឡែកផ្សេងទៀតសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃផ្នែកនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ។

សមាសភាពនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥**.-

១-ជនទាំងឡាយណា ដែលត្រូវបានចូលក្នុងរបបសន្តិសុខសង្គម ក្នុងរយៈពេលយ៉ាងតិចប្រាំមួយ (៦) ខែ ជាបន្តបន្ទាប់មកហើយៗអស់លទ្ធភាពបំពេញលក្ខខណ្ឌ នៃការបញ្ចូលក្នុងរបបសន្តិសុខសង្គមនៃច្បាប់នេះ ប៉ុន្តែចង់បន្តដោយស្ម័គ្រចិត្តនៅក្នុងផ្នែកសោធនតទៅទៀត ត្រូវដាក់ពាក្យសុំក្នុងរយៈពេលបីខែក្រោយពីថ្ងៃដែលខ្លួនបានបញ្ចប់កាលបរិច្ឆេទ តាមសេចក្តីតំរូវនៃការបញ្ចូលទៅក្នុងរបបនេះ ។

២-បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់អំពីបែបបទអនុវត្ត ចំពោះការធានារ៉ាប់រងផ្នែកសោធនតាមការស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៦**.-

និយោជក និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវមានកាតព្វកិច្ចបង់ភាគទានជូនដល់ **ប.ស.ស** ។ បែបបទ និងនីតិវិធីនៃការបង់ភាគទាន និងការទទួលតាវកាលិក ត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការបង្កើត **ប.ស.ស** ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ។

## **ជំពូកទី ២**
## **ផ្នែកប្រាក់សោធន**

**មាត្រា ៧**.-

តាវកាលិកនៃផ្នែកប្រាក់សោធនមានជាអាទិ៍ សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក ។

**មាត្រា ៨**.-

១-សមាជិក **ប.ស.ស** ដែលមានអាយុ ៥៥ ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនជរាភាព ប្រសិនបើជននោះបានបំពេញលក្ខខណ្ឌដូចតទៅ ៖

ក-ចុះឈ្មោះក្នុងបញ្ជីនៃ **ប.ស.ស** ក្នុងថិរវេលាយ៉ាងតិចម្ភៃ (២០) ឆ្នាំ ។

ខ-បានបង់ភាគទានយ៉ាងតិចបំផុតហុកសិប(៦០) ខែ សម្រាប់របបសន្តិសុខសង្គម ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយ គិតរហូតមកទល់កាលបរិច្ឆេទ ដែលមានសិទ្ធិត្រូវបានទទួលប្រាក់សោធន ។

២-សមាជិក **ប.ស.ស** ដែលមានការចុះទន់ខ្សោយសម្បទាមុនអាយុ ៥៥ ឆ្នាំ ទោះជាខាងស្មារតីក្តី ឬរាងកាយក្តី បណ្តាលឱ្យបាត់បង់សមត្ថភាពការងារ ដែលទទួលបានប្រាក់ឈ្នួល ប៉ុន្តែបានបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះ អាចស្នើសុំប្រាក់សោធនកាលាទិករណ៍បាន។ បែបបទនៃការកំណត់និងការត្រួតពិនិត្យភាពចុះទន់ខ្សោយសម្បទាមុនអាយុ ៥៥ ឆ្នាំ ត្រូវចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

៣-ប្រាក់សោធនជរាភាព និងប្រាក់សោធនកាលាទិករណ៍មានប្រសិទ្ធភាព នៅថ្ងៃទីមួយនៃខែតាមប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលសាមីជនបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវរួចហើយ ប្រសិនបើសាមីជននោះបានផ្ញើពាក្យ

ស៊ុំមក **ប.ស.ស** ក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីកាលបរិច្ឆេទដូចពោលខាងលើ ។ ក្នុងករណីដែលពាក្យសុំប្រាក់សោធនធ្វើនៅក្រោយចិរវេលា ដូចមានចែងខាងលើ ប្រាក់សោធននឹងត្រូវមានប្រសិទ្ធភាពនៅថ្ងៃទីមួយ នៃខែតាមប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទនៃថ្ងៃដែលបានទទួលពាក្យសុំ ។

៤-សមាជិក **ប.ស.ស** ដែលមានអាយុ ៥៥ ឆ្នាំ បានបង់ភាគទានតិចជាងហុកសិប (៦០) ខែ សម្រាប់របបសន្តិសុខសង្គម ថែមទាំងបានបញ្ចប់គ្រប់ការងារដែលអាចទទួលបានប្រាក់ឈ្នួល ប៉ុន្តែមិនទាន់បានបំពេញលក្ខខណ្ឌផ្សេងទៀតដើម្បីអាចទទួលបានប្រាក់សោធនជរាភាព ត្រូវមានសិទ្ធិទទួលវិភាជន៍ជរាភាពដែលត្រូវបើកឱ្យតែម្តងគត់ ។

**មាត្រា ៩**.-

សមាជិក **ប.ស.ស** ដែលធ្លាក់ក្នុងទុព្វលភាពមុនអាយុ ៥៥ ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចតទៅ ៖

ក-មានឈ្មោះក្នុងបញ្ជីនៃ **ប.ស.ស** យ៉ាងតិចប្រាំ (៥) ឆ្នាំ ។

ខ-បានបង់ភាគទានចំនួនប្រាំមួយ (៦) ខែ សំរាប់របបសន្តិសុខសង្គមក្នុងអំឡុងពេលដប់ពីរ (១២) ខែចុងក្រោយ ដោយគិតមកទល់ថ្ងៃដែលសាមីជនចាប់ផ្តើមបាត់បង់សមត្ថភាពការងារដោយសារទុព្វលភាព ។

**មាត្រា ១០**.-

ប្រសិនបើ សាមីជននៃសោធនជរាភាព ឬទុព្វលភាព ឬសោធនកាលាទិករណ៍ទទួលមរណភាព ឬក៏ក្នុងករណីដែលសមាជិក **ប.ស.ស** ទទួលមរណភាព ហើយដែលនៅក្នុងកាលបរិច្ឆេទនៃមរណភាពនេះ ជននោះបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការទទួលយកអត្ថប្រយោជន៍ពីសោធនជរាភាព ឬទុព្វលភាព ឬក៏បានបង់ភាគទានចំនួនមួយរយប៉ែតសិប (១៨០) ខែ សម្រាប់របបសន្តិសុខសង្គមរួចហើយ អ្នកសិទ្ធិវន្តនៃជនទាំងនោះមានសិទ្ធិទទួលបាននូវសោធនចំពោះអ្នកនៅក្នុងបន្ទុក ។

**មាត្រា ១១**.-

ប្រសិនបើសមាជិក **ប.ស.ស** មិនអាចមានសិទ្ធិទទួលនូវប្រាក់សោធន ទុព្វលភាពបាន និងមិនទាន់បានបង់ភាគទានគ្រប់ចំនួនមួយរយប៉ែតសិប (១៨០) ខែសំរាប់របបសន្តិសុខសង្គម គិតមកទល់នឹងថ្ងៃដែលខ្លួនទទួលមរណភាពទេនោះ ប្តី ឬប្រពន្ធដែលជាទុព្វលជនក្តី ឬមិនមែនក្តី ព្រមទាំងកូនកំព្រានៃសាមីជន ត្រូវមានសិទ្ធិទទួលអត្ថប្រយោជន៍ជាវិភាជន៍ ចំពោះអ្នកនៅក្នុងបន្ទុកដែលបើកឱ្យតែម្តងគត់ ក្នុងចំនួនមិនតិចជាងប្រាក់សោធនជរាភាពប្រចាំខែសំរាប់សមាជិក **ប.ស.ស** នោះ ។

## ជំពូកទី ៣
## ផ្នែកហានិភ័យការងារ

**មាត្រា ១២**.-

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ ។

ម្យ៉ាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

**មាត្រា ១៣**.-

១-ជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ ក៏ត្រូវចាត់ទុកថាជាហានិភ័យការងារដែរ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងរដ្ឋមន្ត្រី

ក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមស្តីពី ការកំណត់បញ្ជីជំងឺវិជ្ជាជីវៈ ដោយមានភ្ជាប់មកជាមួយនូវបញ្ជីានៃមុខរបរប្រើកំលាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឱ្យអ្នកធ្វើការកើតជំងឺផ្សេងៗ បន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាបច្ចេកទេស ។

២-បញ្ជីានេះត្រូវសើរើពិនិត្យឡើងវិញជាកាលិក ដើម្បីកែលំអបច្ចេកទេសឱ្យបានជឿនលឿន និងជំរុញការយល់ដឹងខាងវេជ្ជសាស្រ្ត សម្រាប់ជាមូលដ្ឋានក្នុងការទប់ស្កាត់គ្រោះថ្នាក់ជំងឺវិជ្ជាជីវៈ ។

៣-ជំងឺដែលគេបានប្រកាសថាជាហានិភ័យការងារ ក្រោយពីកាលបរិច្ឆេទ ដែលកម្មករនិយោជិតបានឈប់ធ្វើការងារហើយនោះ ក៏អាចបើកសិទ្ធិឱ្យអ្នករងគ្រោះទទួលតាវកាលិកសម្រាប់ហានិភ័យការងារបានដែរ បើការប្រកាសនោះស្ថិតក្នុងអំឡុងពេលដែលមានបញ្ជាក់ក្នុងបញ្ជីនៃជំងឺវិជ្ជាជីវៈ ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ ខាងលើ ។

**មាត្រា ១៤**.-

១-អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនៃនិយោជកនោះអំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ៍ ឬការមិនមានលទ្ធភាពជាស្ថាពរ ឬក៏មានមូលហេតុសមហេតុសមផល។ កាតព្វកិច្ចដូចគ្នានេះដែរ បើក្នុងករណីមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិតត្រូវធ្លាក់ទៅលើអ្នកសិទ្ធិវន្ត ។

២-និយោជកត្រូវជូនដំណឹងទៅ **ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំបី (៤៨) ម៉ោង ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលធ្លាក់លើរូបកាយនិយោជិតកម្មករ ដែលធ្វើការក្នុងសហគ្រាសរបស់ខ្លួន ។ ការជូនដំណឹងនេះ ត្រូវធ្វើតាមទំរង់បែបបទ ដែលមានកំណត់ក្នុងប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល

តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

៣-បែបបទនៃការត្រួតពិនិត្យ និងកាតព្វកិច្ចនៃអ្នករងគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល ។

**មាត្រា ១៥**.-

តាវកាលិកនៃហានិភ័យការងារមាន ៖

ក-ការថែទាំ និងព្យាបាលមុខរបួសដែលបណ្ដាលមកពីគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ទោះបីគ្រោះថ្នាក់នោះបណ្ដាលឱ្យមានការអាក់ខានធ្វើការក្ដី ឬគ្មានក្ដី ។

ខ-ការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់គ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាបណ្ដោះអាសន្ន ។

គ-ការផ្ដល់ធនលាភ ឬប្រាក់វិភាជន៍ សម្រាប់ការបាត់បង់សមត្ថភាពការងារ ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។

ឃ-ការផ្ដល់ប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព និងធនលាភចំពោះឧត្តរជីវីនៃជនរងគ្រោះ ។

**មាត្រា ១៦**.-

ការថែទាំ និងព្យាបាលមានជាអាទិ៍ដូចខាងក្រោម ៖

ក-ការជួយរ៉ាប់រងក្នុងការព្យាបាល ការវះកាត់ កិច្ចការទន្តសាស្ត្រ ព្រមទាំងការពិនិត្យដោយវិទ្យុកាំរស្មី ការពិនិត្យរបស់មន្ទីរពិសោធន៍ និងការវិភាគផ្សេងៗ ។

ខ-ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាល និងសំភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល ។

គ-ការផ្តល់ប្រាក់ឧបត្ថម្ភ សម្រាប់ការថែទាំអ្នករងគ្រោះនៅក្នុងមន្ទីរពេទ្យ ឬក្នុងទីផ្សេងទៀត ។

ឃ-ការផ្គត់ផ្គង់ ការថែទាំ ឬជួសជុលជាថ្មីនូវឧបករណ៍អវយវៈសិប្បនិម្មិត ឬការកែទម្រង់កាយដោយគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** តម្រូវឱ្យធ្វើ ឬការកែលំអសំរបសំរួលមុខងារ ឬការអប់រំវិជ្ជាជីវៈឡើងវិញ ។

ង-ការសម្របសម្រួលមុខងារ ការអប់រំវិជ្ជាជីវៈឡើងវិញ ការចាត់ថ្នាក់ការងារឡើងវិញតាមលក្ខខណ្ឌ ដែលកំណត់ដោយប្រកាស នៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

ច-ការដឹកជនរងគ្រោះពីកន្លែងគ្រោះថ្នាក់ ទៅកាន់កន្លែងព្យាបាល ឬទៅកាន់លំនៅស្ថាន ។

**មាត្រា ១៧**.-

ក្នុងករណីដែលមាន ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្នដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** អ្នករងគ្រោះមានសិទ្ធិទទួលនូវប្រាក់បំណាច់ប្រចាំថ្ងៃ ។ ប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវបើកឱ្យអ្នករងគ្រោះរហូតដល់ថ្ងៃដែលមុខរបួសបានជាសះស្បើយ ឬដល់ថ្ងៃដែលអ្នករងគ្រោះទទួលមរណភាព ដោយសារមុខរបួស បន្ទាប់ពីមានការព្យាបាលមួយរយៈពេលមក ។ ប្រាក់ឈ្នួលប្រចាំថ្ងៃរបស់កម្មករនិយោជិតសម្រាប់ថ្ងៃផ្អាកការងារដំបូងត្រូវនៅក្នុងបន្ទុករបស់និយោជក ។

**មាត្រា ១៨**.-

បន្ទាប់ពីមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** ថាខ្លួនបានបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មកអ្នករងគ្រោះមានសិទ្ធិទទួលបាននូវ ៖

ក-ធនលាភ សម្រាប់ការបាត់បង់សមត្ថភាពការងារជា

អចិន្ត្រៃយ៍ ប្រសិនបើកម្រិតនៃការបាត់បង់សមត្ថភាពការងារមានយ៉ាងតិចស្មើនឹង ម្ភៃភាគរយ (២០%) ។

ខ-ប្រាក់វិភាជន៍សំរាប់ការបាត់បង់សមត្ថភាពការងារ ដែលត្រូវបើកឱ្យតែម្តងគត់ ប្រសិនបើកម្រិតនៃការបាត់បង់សមត្ថភាពការងារនោះតិចជាង ម្ភៃភាគរយ (២០%) ។

កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

**មាត្រា ១៩**.-

ក្នុងករណីមាន ហានិភ័យការងាររហូតបណ្តាលឱ្យអ្នករងគ្រោះបាត់បង់ជីវិត បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់ប្រាក់វិភាជន៍សំរាប់ជាសោហ៊ុយបូជាសព និងប្រាក់ធនលាភចំពោះអ្នកសិទ្ធិវន្តនៃជនរងគ្រោះ ។

**មាត្រា ២០**.-

ឧត្តរជីវីនៃជនរងគ្រោះ គឺជនទាំងអស់ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

ក-ប្រពន្ធ ឬប្តីមិនមានការលែងលះ ឬក៏បែកបាក់គ្នា បានរៀបការពេញច្បាប់ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ ឬមុនពេលជនរងគ្រោះបាត់បង់ជីវិត ទោះជាការរៀបការនេះធ្វើឡើងក្រោយពេលដែលមានគ្រោះថ្នាក់ការងារក៏ដោយ ។

ខ-កូនទាំងអស់ដែលនៅក្នុងបន្ទុកនៃអ្នករងគ្រោះ ដែលត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពី ការបង្កើត **ប.ស.ស** ។

គ-ឪពុកម្តាយ ឬមនុស្សចាស់ជរា ដែលស្ថិតនៅក្រោមអាណាព្យាបាល និងនៅក្នុងបន្ទុកដោយផ្ទាល់នៃអ្នករងគ្រោះក្នុងឱកាសដែលមានគ្រោះថ្នាក់ ។

**មាត្រា ២១**.-

១-ចំពោះសមាជិក **ប.ស.ស** ដែលបានទទួលប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ប៉ុន្តែត្រូវរងនូវហានិភ័យការងារជាថ្មីម្តងទៀត ត្រូវមានការគិតគូរឡើងវិញនូវចំនួនប្រាក់ធនលាភថ្មី ដោយផ្អែកលើកម្រិតនៃការបាត់បង់សមត្ថភាពការងារថ្មីនោះ ។ ទោះជាយ៉ាងនេះក៏ដោយ បើក្នុងពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលប្រាក់ឈ្នួលមូលដ្ឋានមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់ឈ្នួលនេះ សម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ធនលាភថ្មី ។

២-ចំពោះសមាជិក **ប.ស.ស** ដែលកំពុងទទួលប្រាក់វិភាជន៍ដោយការបាត់បង់សមត្ថភាពការងារ ប៉ុន្តែត្រូវរងហានិភ័យការងារជាថ្មីបណ្តាលឱ្យបាត់បង់សមត្ថភាពការងារយ៉ាងតិចម្ភៃភាគរយ (២០%) ជននេះមានសិទ្ធិទទួលនូវប្រាក់ធនលាភតាមកម្រិតបាត់បង់សមត្ថភាពការងារជាក់ស្តែងរបស់ខ្លួន ។ បើនៅពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលបានប្រាក់ឈ្នួលមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់ឈ្នួលនេះ សម្រាប់គណនាប្រាក់ធនលាភ ។

៣-គ្រប់ករណីទាំងអស់ប្រាក់ធនលាភសំរាប់ការបាត់បង់សមត្ថភាពការងារនៅតែចាត់ទុកថាជាប្រាក់បណ្តោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាពជាកាលិកចំពោះអ្នករងគ្រោះដែលទទួលប្រាក់ធនលាភសំរាប់ការបាត់បង់សមត្ថភាពការងារ ។

អ្នករងគ្រោះ មិនអាចជំទាស់នឹងការពិនិត្យសុខភាព ដែលធ្វើឡើងតាមបញ្ជារបស់ បេឡាជាតិរបបសន្តិសុខសង្គមបានឡើយ ។

**មាត្រា ២២**.-

នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីសកម្មភាពសុខាភិបាល និងសង្គមកិច្ច **ប.ស.ស** ត្រូវរៀបចំឱ្យមានការបង្ការចំពោះហានិភ័យការងារមានជាអាទិ៍ វិធានការផ្អែកអនាម័យ និងសន្តិសុខការងារចំពោះកម្មករនិយោជិតដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ និងអត្ថបទណែនាំអនុវត្តច្បាប់នេះ ។

# ជំពូកទី ៤
# បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២៣**.-

បែបបទនៃការចូលរួមរបស់និយោជក ការចុះឈ្មោះនៃកម្មករនិយោជិត ការបង់ភាគទាន ការទូទាត់តាវកាលិក និងសេវានៃតាវកាលិក ដែលត្រូវធ្លាក់មកក្នុងបន្ទុករបស់និយោជក និងកម្មករនិយោជិតនៅក្នុងដំណើរប្រព្រឹត្តទៅនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

**មាត្រា ២៤**.-

១-មូលនិធិផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ចរបស់ **ប.ស.ស** ត្រូវបានផ្គត់ផ្គង់ដោយប្រាក់ ដែលជាផលកំរៃនៃប្រាក់ពិន័យដោយសារការយឺតយូររបស់និយោជកក្នុងការមកបង់ភាគទាន និងការផ្តល់តារាងបៀវត្សមិនទាន់តាមកាលកំណត់ ព្រមទាំងប្រាក់បម្រុងដែលបានកាត់ទុកមុនពីប្រាក់ចំណូលដទៃទៀតរបស់ **ប.ស.ស** ។

២-**ប.ស.ស** អាចប្រើប្រាស់ធនធាននានារបស់មូលនិធិខាងសុខាភិបាល និងសង្គមកិច្ចសម្រាប់ ៖

ក-ធ្វើសកម្មភាពនានាក្នុងគោលដៅសម្រាប់ការបង្ការទូទៅ ការបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ការសម្របសម្រួលវិជ្ជាជីវៈ ជាពិសេសសម្រាប់ការសិក្សាស្រាវជ្រាវ និងធ្វើស្ថិតិហានិភ័យការងារ ព្រមទាំងការឃោសនាផ្សព្វផ្សាយដើម្បីជំរុញឱ្យវិធានការបង្ការ និងសម្រួលវិជ្ជាជីវៈមានការអភិវឌ្ឍន៍ ។

ខ-ផ្តល់ជំនួយខាងហិរញ្ញវត្ថុ ឬចូលរួមជាមួយស្ថាប័នសាធារណៈ ឬអង្គការឯកជនក្នុងវិស័យសុខាភិបាល និងសង្គមកិច្ចដែលមានសកម្មភាពជាប្រយោជន៍សម្រាប់សមាជិក **ប.ស.ស** នៃផ្នែកនីមួយៗ ។

**មាត្រា ២៥**.-

១-រយៈពេលដែលបើកសិទ្ធិឱ្យសមាជិក **ប.ស.ស** ទទួលបានតាវកាលិក គឺរយៈពេលទាំងឡាយណាដែលសមាជិកនោះបានទទួលប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ ឬរយៈពេលបាត់បង់សមត្ថភាពការងារដែលមិនលើសពីប្រាំមួយ (៦) ខែ ក្នុងករណីមានជំងឺដែលមានការបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ **ប.ស.ស** ឬរយៈពេលដែលអវត្តមានក្នុងឱកាសឈប់សំរាកធម្មតា ដោយគិតទាំងរយៈពេលធ្វើដំណើរដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារផងដែរ ។

២-ពាក្យថា "ខែ" សម្រាប់របបសន្តិសុខសង្គមគឺជាខែដែលសមាជិក **ប.ស.ស** បានបំពេញការងារមានរយៈពេលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់បែបបទអនុវត្តក្នុងផ្នែកនេះ ព្រមទាំងលក្ខខណ្ឌសម្រាប់ការកំណត់អំពី "ខែ" សម្រាប់របបសន្តិសុខសង្គម ។

**មាត្រា ២៦**.-

ប្រាក់ធនលាភ និងប្រាក់សោធនទាំងអស់ត្រូវគណនាតាមចំនួនប្រចាំខែ ។ ការគណនាប្រចាំខែនេះ ត្រូវកំណត់តាមស្ថានភាពនៃសមាជិក **ប.ស.ស** គឺនៅថ្ងៃទីមួយនៃខែដែលត្រូវគ្នា ។ ចំនួនទឹកប្រាក់ប្រចាំខែនីមួយៗត្រូវបង្កើន ឬបន្ថយតាមខ្ទង់រយដែលជិតជាង ។

ការបើកប្រាក់ធនលាភ និងប្រាក់សោធនត្រូវធ្វើប្រចាំត្រីមាស ។

**មាត្រា ២៧**.-

១-សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសពត្រូវអស់សុពលភាពត្រឹមរយៈពេលមួយ (១) ឆ្នាំ ។

២-សិទ្ធិនៃការទាមទារប្រាក់ធនលាភនិងប្រាក់សោធន ព្រមទាំងវិភាជន៍ជរាភាព ទុព្វលភាព និងមរណភាពត្រូវអស់សុពលភាពត្រឹមរយៈពេលប្រាំ (៥) ឆ្នាំ ។

**មាត្រា ២៨**.-

ជនដែលបានទទួលប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារ ឬប្រាក់សោធនទុព្វលភាពណាម្នាក់ ដែលតម្រូវឱ្យមានអ្នកចាំថែរក្សាមានសិទ្ធិទទួលបានការឧបត្ថម្ភបន្ថែមចំនួនហាសិប (៥០%) ភាគរយនៃចំនួនប្រាក់ធនលាភ ឬប្រាក់សោធននោះ ។

**មាត្រា ២៩**.-

តាវកាលិកទាំងអស់មិនអាចផ្ទេរ ឬរឹបអូសបានទេលើកលែងតែមានលក្ខខណ្ឌ និងការកម្រិតដូចគ្នានឹងការផ្ទេរ ឬរឹបអូសប្រាក់ឈ្នួលដែលមានចែងនៅក្នុងច្បាប់ស្ដីពីការងារ ។

**មាត្រា ៣០**.-

ក្នុងករណីដែលមានអត្ថប្រយោជន៍ត្រួតគ្នា ទោះជាអត្ថប្រយោជន៍ខាងប្រាក់សោធនក្ដី ឬប្រាក់ធនលាភក្ដី អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ សាមីជនមានសិទ្ធិទទួលបានប្រាក់សោធន ឬប្រាក់ធនលាភណាដែលមានចំនួនទឹកប្រាក់ខ្ពស់ជាងគេ ។

**មាត្រា ៣១**.-

វិវាទ ឬបណ្ដឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាខាងវិស័យរបបសន្តិសុខសង្គមរវាងសមាជិក **ប.ស.ស** និយោជក និង **ប.ស.ស** ដែលមិនអាចដោះស្រាយបាន ដោយការផ្សះផ្សារបស់គណកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃ **ប.ស.ស** ត្រូវនៅក្រោមសមត្ថកិច្ចនៃតុលាការ ដែលសមាជិក **ប.ស.ស** ឬនិយោជករស់នៅ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់អំពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃ **ប.ស.ស** ។

**មាត្រា ៣២**.-

១-ត្រូវបង្កើតឱ្យមាន ប្រព័ន្ធសម្របសម្រួលមួយរវាងផ្នែកនីមួយៗ ដែលបង្កើតឡើងដោយច្បាប់នេះ ជាមួយនឹងគ្រប់របបធានារ៉ាប់រងនៃផ្នែកសាធារណៈ ដើម្បីធ្វើឱ្យមានសុពលភាពក្នុងការចូលនិវត្តន៍នៃសេវាដែលមានពីមុនមក និងមានសុពលភាពនៃរយៈពេលធានារ៉ាប់រងក្នុងករណីមានការផ្លាស់ប្តូរលក្ខន្តិកៈ ឬរបបធានារ៉ាប់រងនៃភ្នាក់ងារណាមួយ ។

២-បែបបទនៃការអនុវត្តប្រព័ន្ធសម្របសម្រួលនេះ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

**មាត្រា ៣៣**.-

បេឡាជាតិរបបសន្តិសុខសង្គមត្រូវរួចផុតពីការបង់ពន្ធ និងអាករគ្រប់យ៉ាង ។ ប៉ុន្តែ ប្រតិបត្តិការរបស់បេឡានេះ ដែលមានចរិតជាពាណិជ្ជកម្ម ហើយដែលមានគោលដៅរកផលចំណេញសុទ្ធសាធ ត្រូវជាប់ពន្ធអាករតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤**.-

ជនប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬក៏ត្រូវផ្តន្ទាទោសទាំងពីរ ។

ការពិន័យជាប្រាក់ ត្រូវដាក់បង្ខំដោយនាយកនៃ **ប.ស.ស** ។

**មាត្រា ៣៥**.-

ការពិន័យជាប្រាក់ ត្រូវកំណត់ជាពហុគុណនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ។ ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ គឺជាប្រាក់ឈ្នួលអប្បបរមាដែលកំណត់

ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣៦**.-

និយោជកណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃមាត្រា ៦ ឬមាត្រា ២៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់ (១០) ថ្ងៃ ទៅសាមសិប (៣០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬបើក្នុងករណីមិនរាងចាល ត្រូវពិន័យពីសាមសិប (៣០) ថ្ងៃ ទៅកៅសិប (៩០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ដោយមិនទាន់គិតដល់ទណ្ឌកម្មចំពោះការបង់ភាគទាន និងប្រាក់ពិន័យដែលត្រូវធ្លាក់លើបន្ទុករបស់និយោជកនោះទេ ។ ការពិន័យនេះ ត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលត្រូវបានគេប្រើប្រាស់ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៧**.-

និយោជកណា ដែលបានដកយកភាគទានពីកម្មករនិយោជិតដោយមិនត្រឹមត្រូវ ដើម្បីដាក់មកក្នុងរបបសោធនដោយការកាត់បន្ថយប្រាក់ឈ្នួលនោះ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ខែ ដល់មួយ (១) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយម្ភៃ (១២០) ថ្ងៃ ទៅបីរយហុកសិប (៣៦០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

ក្នុងករណីមិនរាងចាល ក្នុងអំឡុងពេលបី (៣) ឆ្នាំ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយម្ភៃ (១២០) ថ្ងៃ ទៅបីរយហុកសិប (៣៦០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរនេះ ។

**មាត្រា ៣៨**.-

១-ជនណាក៏ដោយដែលធ្វើឯកសារក្លែងបន្លំដោយចេតនា ដើម្បីចង់បានការផ្តល់តាវកាលិកសំរាប់ខ្លួន ឬតតិយជន ដែលមិនគួរត្រូវបាន ត្រូវផ្តន្ទា

ទោសពិន័យជាប្រាក់ពីហុកសិប (៦០) ថ្ងៃ ទៅកៅសិប (៩០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦) ថ្ងៃ ទៅមួយ (១) ខែ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរនេះ ។ ការដាក់ទណ្ឌកម្មខាងលើនេះ ត្រូវធ្វើដោយមិនទាន់គិតដល់ទោសកំហុសដទៃទៀត ប្រសិនបើជននេះបានប្រព្រឹត្តផងដែរ ។

២-ក្នុងករណីមិនរាងចាលក្នុងអំឡុងមួយ (១) ឆ្នាំ ត្រូវទទួលការដាក់ទណ្ឌកម្មដល់កំរិតអតិបរមា គឺទណ្ឌកម្មទាំងពីររួមគ្នាតែម្តង ។

**មាត្រា ៣៩**.-

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៣៦ និងមាត្រា ៣៧ ខាងលើ តុលាការអាចបញ្ជាឱ្យផ្សព្វផ្សាយនូវសាលក្រមតាមសារពត៌មាន និងបិទប្រកាសផ្សាយនៅតាមទីកន្លែងនានាដែលបានកំណត់ ។ ប្រាក់ចំណាយសម្រាប់ការផ្សព្វផ្សាយនេះ ត្រូវនៅក្នុងបន្ទុករបស់ជនដែលប្រព្រឹត្តល្មើស ។

**មាត្រា ៤០**.-

១-ពាក្យបណ្តឹងសាធារណៈចំពោះការល្មើសរបស់និយោជក ឬអ្នកតំណាងរបស់ខ្លួនលើបទប្បញ្ញត្តិស្តីពីទណ្ឌកម្មដូចមានចែងក្នុងមាត្រា ៣៤ ខាងលើត្រូវមានអាជ្ញាយុកាលរយៈពេលមួយ (១) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតដាក់កំហិតរយៈពេលដប់ប្រាំ (១៥) ថ្ងៃមក ។

២-ពាក្យបណ្តឹងរដ្ឋប្បវេណីចំពោះការទារភាគទាន ឬប្រាក់ពិន័យដោយការយឺតយូរក្នុងការបង់ប្រាក់របស់និយោជកត្រូវមានអាជ្ញាយុកាលរយៈពេលប្រាំ (៥) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតដាក់កំហិតរយៈពេលដប់ប្រាំ (១៥) ថ្ងៃមកដោយមិនមានទាក់ទងនឹងបណ្តឹងសាធារណៈ ឬបន្ទាប់ពីការកន្លងផុតនៃបណ្តឹងសាធារណៈ ។

## **ជំពូកទី ៦**
## **អវសានប្បញ្ញត្តិ**

**មាត្រា ៤១**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

ពរល-០២-០៩-០០២៨៨

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា**

**ហត្ថលេខា**

**អ៊ិត សំហេង**

លេខៈ ១៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**ណារី តាន់**

# ឧបសម្ព័ន្ធទី ២

# អនុក្រឹត្យ ស្ដីពីការបង្កើតបេឡាជាតិរបប សន្តិសុខសង្គម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

# Sub-Decree

## On

## The establishment of National Social Security Fund

# មាតិកា

**ជំពូកទី ១** បទប្បញ្ញត្តិទូទៅ........................................................... ០២

**ជំពូកទី ២** រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម.............................. ០៣

២.១ ផ្នែកទី ១ ក្រុមប្រឹក្សាភិបាល ................................................ ០៣

២.២ ផ្នែកទី ២ អង្គការប្រតិបត្តិនៃ ប.ស.ស.................................... ០៨

**ជំពូកទី ៣** ការគ្រប់គ្រងហិរញ្ញវត្ថុ ...................................................... ១១

៣.១ ផ្នែកទី ១ កិច្ចការគណនេយ្យ ................................................ ១១

៣.២ ផ្នែកទី ២ ប្រភពធនធាន ...................................................... ១២

៣.៣ ផ្នែកទី ៣ ការចំណាយ ......................................................... ១៣

៣.៤ ផ្នែកទី ៤ ប្រាក់ត្រៀមបម្រុង ................................................. ១៤

៣.៥ ផ្នែកទី ៥ មូលនិធិបង្វិល ..................................................... ១៤

៣.៦ ផ្នែកទី ៦ ការវិភាគសន្តិសុខសង្គម .......................................... ១៥

**ជំពូកទី ៤** ភាគទាន និងតាវកាលិកសន្តិសុខសង្គម ............................ ១៥

៤.១ ផ្នែកទី ១ ភាគទាន ............................................................... ១៥

៤.២ ផ្នែកទី ២ តាវកាលិក ........................................................... ១៦

**ជំពូកទី ៥** អាណាព្យាបាល ................................................................. ១៦

៥.១ ផ្នែកទី ១ អាណាព្យាបាលបច្ចេកទេស .................................... ១៦

៥.២ ផ្នែកទី ២ អាណាព្យាលបាលហិរញ្ញវត្ថុ ................................... ១៩

**ជំពូកទី ៦** បទប្បញ្ញត្តិផ្សេងៗ ............................................................. ២១

**ជំពូកទី ៧** អន្តរប្បញ្ញត្តិ ...................................................................... ២៣

**ជំពូកទី ៨** អវសានប្បញ្ញត្តិ .................................................................. ២៣

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "**ប.ស.ស**"។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ស.ស** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

**ប.ស.ស** គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

**ប.ស.ស** ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៣.-**

**ប.ស.ស** មានភារកិច្ចដូចខាងក្រោម ÷

១- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

២- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ**ប.ស.ស** ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។

៣- ប្រមូលភាគទានពីសមាជិកនៃ**ប.ស.ស** និងនិយោជក ។

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី ÷

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និង អនាម័យការងារ ។

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ ។

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

## ជំពូកទី ២

## រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**ប.ស.ស**ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ។

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ ( មួយ )រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ ( មួយ )រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១( មួយ )រូប | សមាជិក |
| - តំណាងនិយោជក ២(ពីរ) រូប | សមាជិក |
| - តំណាងកម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ២(ពីរ)រូប | សមាជិក |
| - នាយកនៃ **ប.ស.ស** | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃ **ប.ស.ស** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ÷

- អនុម័តថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ជាពិសេសសម្រាប់តាវកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច

- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្ដីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្ដល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្ដីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ។

**មាត្រា ៦.-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្ដន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន ។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬ នីតិសាស្ត្រ និង មិនដែលត្រូវបានផ្ដន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី)ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះ តំណាងឱ្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣(បី)ខែ។ ទោះជាមានកំណត់ដូច្នេះក្តី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ម.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើរបស់នាយកនៃ**ម.ស.ស** ឬ សមាជិកដែលមានចំនួន ៥ (ប្រាំ) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ម.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុង សម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ម.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិក ក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិន បើខ្វះកូរ៉ុមការប្រជុំត្រូវលើកទៅ ១៥(ដប់ប្រាំ)ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជា ការបាន លុះណាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

**មាត្រា ៨.-**

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ម.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០(ដប់) ថ្ងៃយ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសំគាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងអស់នោះ ក្នុងកំណត់ហេតុនៃកាប្រជុំចុងក្រោយនេះផង។

**មាត្រា ៩.-**

លាភការនៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

**មាត្រា ១០.-**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោម ÷

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬ មានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ**ប.ស.ស** ឬ បម្រើសេវាកម្មណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល ។

សមាជិកក្រុមប្រឹក្សាភិបាលរូបណាដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាលដែលបាត់បង់សមាជិកភាពរបស់ខ្លួនត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិនៃ ប.ស.ស

**មាត្រា ១១.-**

នាយកនៃ**ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នាយកនៃ**ប.ស.ស** មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់**ប.ស.ស** ។

មាត្រា ១២.-

នាយកនៃប.ស.សត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃប.ស.សក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ប.ស.ស និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃប.ស.ស មានភារកិច្ចសំខាន់ៗដូចតទៅ ÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ ប.ស.ស
- ទទួលបន្ទុកដឹកនាំ ប.ស.ស ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ស.ស ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបរបស់ ប.ស.ស ដោយគោរពតាម លក្ខន្តិកៈ ឬ ច្បាប់ជាធរមាន និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬ ផ្តល់លាភការដល់បុគ្គលិករបស់ ប.ស.ស ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការ ស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់មន្ត្រីរាជការ នៃ ប.ស.ស ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ មន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ ប.ស.សចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ ប.ស.ស និង ទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ ប.ស.ស។

នាយកនៃ ប.ស.ស មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១៣.-**

គណនេយ្យករនៃ **ប.ស.ស** ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពគ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃ **ប.ស.ស**។

**មាត្រា ១៤.-**

ការត្រួតពិនិត្យនូវការអនុវត្តបទប្បញ្ញត្តិនៃ "ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" នៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើដោយអធិការឬអភិបាលរបបសន្តិសុខសង្គម និងក្នុងករណីចាំបាច់ត្រូវសហការជាមួយអធិការការងារ ឬអភិបាលការងារ និងអង្គភាពពាក់ព័ន្ធដទៃទៀត។

ការតែងតាំង ការកំណត់តួនាទីភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

**មាត្រា ១៥.-**

បុគ្គលិកអចិន្ត្រៃយ៍របស់**ប.ស.ស**រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬ មន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ **ប.ស.ស**។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

បេឡាជាតិរបបសន្តិសុខសង្គមអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

បុគ្គលិកនៃ **ប.ស.ស**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៦.-**

រចនាសម្ព័ន្ធគ្រប់គ្រងនៃ**ប.ស.ស**ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

# ជំពូកទី ៣
# ការគ្រប់គ្រងហិរញ្ញវត្ថុ

## ផ្នែកទី ១
## កិច្ចការគណនេយ្យ

**មាត្រា ១៧.-**

**ម.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-**

**១៨.១-** នាយកនៃ **ម.ស.ស** ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរដ្ឋទេយ្យចំណូល ឬបុរេប្រទានបានដោយមានការយល់ព្រមពីគណនេយ្យករ ។

**១៨.២-** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់**ម.ស.ស** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នក ពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ ។

**១៨.៣-** គណនេយ្យករមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

**១៨.៤-** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន ។

**មាត្រា ១៩.-**

នៅរៀងរាល់ឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់**ប.ស.ស**តាមសំណើរបស់នាយកនៃគ្រឹះស្ថាននេះ ។ កម្មវិធី និងគម្រោងទាំងនេះត្រូវបញ្ជូនទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ប្រភពធនធាន

**មាត្រា ២០.-**

ប្រភពធនធាននៃ **ប.ស.ស** មានដូចខាងក្រោម ÷

១- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត **ប.ស.ស** ។

២- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ។

៣- ភាគទានរបស់សមាជិកនៃ **ប.ស.ស** និង និយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ។

៤- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ ។

៥- ផលចំណេញដែលបានមកពីការវិនិយោគ ។

៦- អំណោយ និងអច្ច័យទានផ្សេងៗ ។

៧- ប្រភពធនធានដទៃទៀតដែល **ប.ស.ស** អាចទទួលបានស្របតាមច្បាប់ ។

## ផ្នែកទី ៣
## ការចំណាយ

**មាត្រា ២១.-**

ការចំណាយរបស់**ប.ស.ស** រួមមាន ÷

១- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ ។

២- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃ **ប.ស.ស** ។

៣- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច ។

៤- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ **ប.ស.ស** ។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ៤
## ប្រាក់ត្រៀមបម្រុង

**មាត្រា ២២.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង ១/២(មួយភាគពីរ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល ២(ពីរ) ឆ្នាំចុងក្រោយ ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីបានទទួលសំណើ ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

អត្រាភាគទានដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យឡើងវិញក្នុងករណីដែលប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗធ្លាក់ចុះទាបជាងកម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា ។

## ផ្នែកទី ៥

## មូលនិធិបម្រុង

**មាត្រា ២៣.-**

ត្រូវបង្កើតឱ្យមានមូលនិធិបម្រុងរួមមួយសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម ។ មូលនិធិនេះមិនត្រូវតិចជាង២(ពីរ) ដងនៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ **ប.ស.ស** នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។

## ផ្នែកទី ៦

## ការវិភាគសន្តិសុខសង្គម

**មាត្រា ២៤.-**

**ប.ស.ស** ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្តិសុខសង្គមយ៉ាងយូរបីឆ្នាំម្តង ។ ក្នុងករណីដែលការវិភាគនេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ **ប.ស.ស**ត្រូវស្នើសុំធ្វើការកែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើការរបស់ **ប.ស.ស** ។

រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ស.ស** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា ។

## ជំពូកទី ៤

## ភាគទាន និងតាវកាលិកសន្តិសុខសង្គម

## ផ្នែកទី ១

## ភាគទាន

**មាត្រា ២៥.-**

អត្រានៃភាគទានសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ២

## តាវកាលិក

**មាត្រា ២៦.-**

អត្រានៃតាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

ទម្រង់នៃការស្នើសុំតាវកាលិកទាំងអស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

## ជំពូកទី ៥

## អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៧.-**

**២៧.១-** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយកនៃ**ប.ស.ស**ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយនាយកនៃ **ប.ស.ស** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២** -លិខិតយល់ព្រមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើជូនទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។នាយកនៃ**ប.ស.ស** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ ។

កម្មវិធីអភិវឌ្ឍនៃ**ប.ស.ស** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើងដោយប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា១២(ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។ ទោះជាយ៉ាងនេះក្តី ថវិកាចំណាយសម្រាប់តាវកាលិកដែលត្រូវផ្តល់ឱ្យកម្មករនិយោជិតត្រូវដាក់ឱ្យអនុវត្តបាន ។

**មាត្រា ២៨.‑**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនរួមមាន កម្មវិធីអភិវឌ្ឍ គម្រោងថវិកាប្រចាំឆ្នាំ និងកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានរយៈពេល១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងនោះ ។

នាយកនៃ**ប.ស.ស**ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសម្រេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ២៩.‑**

**២៩.១-** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ប.ស.ស** ក្នុងករណីដែលសេចក្តីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់ **ប.ស.ស**
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ៧ ។

**២៩.២-** ការលុបចោល ឬការផ្អាកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុប

ចោល ឬការផ្អាកសេចក្តីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ប.ស.ស**។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះបន្តទៅក្រុមប្រឹក្សាភិបាល **ប.ស.ស** ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុង **ប.ស.ស** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ៣១.-**

**៣១.១-** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ប.ស.ស** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃដែលទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលទទួលបានឯកសារដែលបញ្ជូនមកដោយនាយកនៃ**ប.ស.ស**ដើម្បីសម្រេចផ្តល់ ការយល់ព្រមលើឯកសារនេះ។

**៣១.២-** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវបានសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយនោះ។

**មាត្រា ៣២.-**

សេចក្ដីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ**ប.ស.ស**ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមការផ្ដល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្ដីសម្រេចស្ដីពីការលក់ ឬផ្ទេរសិទ្ធិអចលទ្រព្យ
- សេចក្ដីសម្រេចស្ដីពីការលើកលែងគណនេយ្យដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្ដីសម្រេចស្ដីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬ លិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣៣.-**

ត្រូវដាក់ឱ្យនៅអមប.ស.សនូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនេះ មានភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្ដាខេត្ត ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើ **ប.ស.ស** ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្ដាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ប.ស.ស** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦

## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៣៤.-**

**៣៤.១**- សិទ្ធិវន្តរបស់សមាជិកនៃ **ប.ស.ស** ដែលត្រូវទទួលបាន "គាវកាលិកឧត្តរជីវី" ត្រូវកំណត់ដូចខាងក្រោម ÷

ក-ប្ដី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្ដីឬប្រពន្ធ ដែលជាសមាជិកនៃ **ប.ស.ស** ។

ខ-កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី) ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាព ដូចខាងក្រោម ÷

- កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ ។ ក្នុងករណីមានការលែងលះ ឬ ករណីមរណភាពនៃប្ដីឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិ ដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ
- កូនចិញ្ចឹមរបស់សមាជិកនៃ **ប.ស.ស** ។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១ (ម្ភៃមួយ) ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ ឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និង មានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬ មានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល ។

គ- ឪពុកម្ដាយ ឬ មនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃ**ប.ស.ស** ។

**៣៤.២-** សិទ្ធិវិន្ទរបស់សមាជិកនៃ**ប.ស.ស**ដែលត្រូវទទួលបាន "តាវកាលិកចំពោះអ្នកនៅក្នុងបន្ទុក" ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈស្ដីពីការរៀបចំតាវកាលិកផ្នែកប្រាក់សោធន ។

**៣៤.៣-** សិទ្ធិធនលាភចំពោះឧត្តរជីវី និងសោធនចំពោះអ្នកនៅក្នុងបន្ទុករបស់សហព័ទ្ធត្រូវផុតរលត់ ក្នុងករណីដែលសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី ។

**មាត្រា ៣៥.-**

**ប.ស.ស** មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលចំណូល ការឱ្យសងបំណុល និងការការពារទ្រព្យសម្បត្តិ ។ បុព្វសិទ្ធិនេះអាចអនុវត្តនៅពេល ដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬ ត្រូវបានជម្រះបញ្ជីដោយតុលាការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមរបស់តុលាការ ។ នីតិវិធីនៃការទារបំណុលរបស់**ប.ស.ស** ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

ភ្នាក់ងារមានសមត្ថកិច្ចតាមច្រក ត្រូវហាមឃាត់មិនឱ្យចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនណា ដែលមិនទាន់បានសងបំណុលប.ស.សតាមដីការបស់តុលាការ ។

**មាត្រា ៣៦.-**

មូលនិធិរបស់ប.ស.ស ត្រូវដាក់ចូលក្នុងគណនី នៅរតនាគាជាតិ ឬនៅធនាគារជាតិនៃកម្ពុជា ឬ នៅធនាគារពាណិជ្ជកម្មផ្សេងៗ ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលនៃប.ស.ស អាចសម្រេចឱ្យប្រើប្រាស់នូវប្រាក់ដែលលើស( ប្រាក់ដែលសល់ពីប្រាក់ត្រៀមបម្រុង)សម្រាប់ការវិនិយោគ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

រដ្ឋធានាចំពោះតែបំណុលរបស់ប.ស.ស ណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៨.-**

ដំណាក់កាល វិសាលភាព នីតិវិធី និងកាលបរិច្ឆេទដាក់លាក់សម្រាប់ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩.-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន នាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្ទេរទៅជាបេឡាជាតិរបបសន្តិសុខសង្គម ។ ប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលតួនាទីជានាយកនៃបេឡាជាតិរបបសន្តិសុខសង្គម រហូតមានការតែងតាំងនាយកប.ស.ស ថ្មី ។

# ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤១
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៣
# របាយការណ៍ស្តីពី លទ្ធផលការងារ
# សម្រេចបានឆ្នាំ២០០៩ និង
# ទិសដៅអនុវត្តបន្ត

**បេឡាជាតិរបបសន្តិសុខសង្គម**

**National Social Security Fund**

# របាយការណ៍

# ស្តីពី

# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩

# និងទិសដៅអនុវត្តបន្ត

**ការអនុវត្តរបបសន្តិសុខសង្គមរួមមាន ៖**

**ផ្នែកហានិភ័យការងារ**

**ផ្នែកប្រាក់សោធន**

**ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពស**

# មាតិកា

- ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ........ I
- អង្គការលេខរបស់ ប.ស.ស ........ II

I. សេចក្តីផ្តើម ........ ១

II.លទ្ធផលការងារសម្រេចបាន ឆ្នាំ២០១៩ ........ ២

ក. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

១.ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ........ ២

១.១.ការងារបញ្ជិកា និងភាគទាន ........ ២

១.២.ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម........ ៤

១.៣. ការងារតាវកាលិក ........ ៧

១.៤.ការងារស្តារនីតិសម្បទា........ ១០

២.ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ........ ១១

២.១.ការងារបញ្ជិកា និងភាគទាន ........ ១១

២.២.ការងារតាវកាលិក........ ១២

២.៣.ការងារស្តារនីតិសម្បទា ........ ១៣

៣.ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ........ ១៤

ខ. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

១. ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ........ ១៤

២. ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

២.១.ការងារបញ្ជិកា និងភាគទាន ........ ១៤

២.២.ការងារតាវកាលិក........ ១៥

២.៣. ការងារស្តារនីតិសម្បទា........ ១៥

គ. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

១.ការងារចុះបញ្ជិកា........ ១៦

២. ការងារតាវកាលិក ........ ១៦

៣.ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិត ជាស្ត្រីនៅពេលសម្រាលកូន ........ ១៦

**ឃ. ការងារគាំទ្រការអនុវត្ត**

**១.ការងាររៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត** ........ ១៧

**២.ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស** ........ ១៧

២.១.ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ........ ១៧

២.២.កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ........ ១៨

២.៣.ការងារព័ត៌មានវិទ្យា ........ ២០

២.៤.ការងារសវនកម្មផ្ទៃក្នុង ........ ២០

២.៥.គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃ ប.ស.ស ........ ២០

**៣. ពង្រឹងការងារផ្សព្វផ្សាយអប់រំ និងបង្ការ**

៣.១.ការពង្រឹងការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម ........ ២១

៣.២.ក្រុមការងារ ប.ស.ស សហការជាមួយក្រុមការងារផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ........ ២១

៣.៣.ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ(ទ.ស.ប.ក) ........ ២១

៣.៤.ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ........ ២២

៣.៥.ការងារផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម ........ ២៣

**III.បញ្ហាប្រឈម** ........ ២៣

**IV.ការដោះស្រាយ និងទិសដៅអនុវត្តបន្ត** ........ ២៤

**V. សេចក្តីសន្និដ្ឋាន** ........ ២៥

**VI. ឧបសម្ព័ន្ធ**

១. ការិយាល័យសាខាបេឡាជាតិរបបសន្តិសុខសង្គមតាមរាជធានី-ខេត្ត/ខណ្ឌ ........ ២៧

២. ចំនួនសហគ្រាស គ្រឹះស្ថានចុះបញ្ជិកាតាមខែ និងតាមរាជធានី-ខេត្ត ........ ២៩

៣. ចំនួនសហគ្រាសចុះបញ្ជិកាថ្មី និងកម្មករនិយោជិត តាមបណ្តារាជធានីខេត្ត ........ ៣០

៤. បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ផ្នែកហានិភ័យការងារ ........ ៣១

៥. បច្ចុប្បន្នភាពសហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើងថ្នាក់កណ្តាល/ថ្នាក់ខេត្ត ........ ៣២

៦. ប្រភេទ និងចំនួនសហគ្រាស គ្រឹះស្ថានបានចុះបញ្ជិកា ........ ៣៣

៧. របាយការណ៍ហានិភ័យការងារ និងលទ្ធផលអង្កេត ........ ៣៦

៨. ស្ថានភាពហានិភ័យការងារតាមកម្រិតរបួស តាមរាជធានី-ខេត្ត ........ ៣៧

៩. លទ្ធផលអង្កេតហានិភ័យការងារតាមប្រភេទគ្រោះថ្នាក់ តាមរាជធានី-ខេត្ត ........ ៣៨

១០. តារាងចំណាត់ថ្នាក់ហានិភ័យការងារតាមសកម្មភាពសេដ្ឋកិច្ច ភេទ និងកម្រិតគ្រោះថ្នាក់ ........ ៣៩

១១. បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ផ្នែកថែទាំសុខភាព ........ ៤៧

១២.បញ្ជីមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ........ ៤៨

## ចក្ខុវិស័យ

ជានាសន្តិសុខសង្គមប្រកបដោយសមធម៌ និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ និងបុគ្គលស្វ័យនិយោជន៍។

## គោលដៅ

ក. ពង្រឹង និងពង្រីកការអនុវត្តផ្នែកហានិភ័យការងារ
ខ. ពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព
គ. រៀបចំ និងដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន
ឃ. សិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការផ្នែកនិកម្មភាពការងារ។

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម ( ប.ស.ស )

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម ( ប.ស.ស )
  - នាយក
    - នាយករង

- ក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំជាក់ស្តែងដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ
- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបញ្ហាគ្រោះថ្នាក់ការងារ ( ទ.ស.ប.ក )
- ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា

- គណៈកម្មការវេជ្ជសាស្ត្រ នៃ បេឡាជាតិរបបសន្តិសុខសង្គម ( ប.ស.ស )
- គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃ ប.ស.ស
- គណៈកម្មការវិនិយោគរបបសន្តិសុខសង្គម នៃ ប.ស.ស
- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិក ( ស.ផ.ក ) នៃ ប.ស.ស

- ការិយាល័យ សម្របសម្រួល និងទំនាក់ទំនងសាធារណៈ
- ការិយាល័យ ស្តារនីតិសម្បទា
- ការិយាល័យ សោធន
- ការិយាល័យ រដ្ឋបាល
- ការិយាល័យ ហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ
- ការិយាល័យ ព័ត៌មានវិទ្យា
- ការិយាល័យ បញ្ជិកា និងភាគទាន
- ការិយាល័យ តាមកាលិក
- ការិយាល័យ អធិការកិច្ច និងកិច្ចការនីតិកម្ម
- ការិយាល័យ សវនកម្មផ្ទៃក្នុង
- ការិយាល័យ គោលនយោបាយ
- ការិយាល័យ ធានារ៉ាប់រងសុខភាព

- សាខា ប.ស.ស ខេត្ត-ខណ្ឌ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត
# របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

## I. សេចក្តីផ្តើម

វិស័យសន្តិសុខសង្គម ក៏ដូចជាវិស័យផ្សេងៗ ត្រូវបានបំផ្លាញទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍។ បន្ទាប់ពីថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ វិស័យនេះត្រូវស្តារឡើងវិញ ប្រព័ន្ធគាំពារសង្គមត្រូវបានអនុវត្តជាបណ្តើរៗ ហើយជាបន្តបន្ទាប់របបសន្តិសុខសង្គម ជាពិសេសផ្នែកប្រាក់សោធន សម្រាប់មន្ត្រីសាធារណៈត្រូវបានបង្កើត និងអនុវត្តរហូតដល់ពេលនេះ។ ច្បាប់ស្តីពីការងារត្រូវបានអនុម័តនៅក្នុងសម័យរដ្ឋកម្ពុជានាឆ្នាំ១៩៩២ និងត្រូវបានរៀបចំឡើងវិញនៅឆ្នាំ១៩៩៧ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានអនុម័តនិងប្រកាសឱ្យប្រើនៅឆ្នាំ២០០២។ ដោយឡែក ប.ស.ស បានអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនៅឆ្នាំ២០០៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់វិស័យឯកជននៅឆ្នាំ២០១៦ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់វិស័យសាធារណៈនៅឆ្នាំ២០១៨ និងអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។ សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់អំពីការរីកចំរើននៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដើម្បីឈានទៅរកប្រព័ន្ធមួយដែលមានលក្ខណៈជាសកល និងសង្គតិភាព ដើម្បីរក្សាបាននូវប្រសិទ្ធភាពនៃការអនុវត្តការងារខាងលើជាប់ជាប្រចាំ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ដែលមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកដែលធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលិកស្វ័យនិយោជន៍ ក្នុងការអនុវត្តរបបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។ ច្បាប់ថ្មីនេះ គឺជាផ្នែកមួយក្នុងការចូលរួមចំណែកអនុវត្តស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣។

ប.ស.ស សង្ឃឹមយ៉ាងមុតមាំថា តាមរយៈលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ នេះ វានឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ សម្រាប់វាស់វែងតាមដាន និងវាយតម្លៃលើការអនុវត្តវិស័យសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការអនុវត្តផ្នែកថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម

សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ហើយវាជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងបញ្ហាប្រឈមនានា ដើម្បីធ្វើការកែតម្រូវ និងធ្វើការដោះស្រាយសម្រាប់រៀបចំទិសដៅអនុវត្តបន្តឱ្យបានកាន់តែល្អប្រសើរថែមទៀត។

## II. លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩

ជាលទ្ធផលសម្រេចបាននៅក្នុងឆ្នាំ២០១៩ បេឡាជាតិរបបសន្តិសុខសង្គម បានចុះបញ្ជិកាសមាជិកសរុបរួមមាន ផ្នែកហានិភ័យការងារចំនួន ៨០ ៧៨៥នាក់ ស្រីចំនួន ៥០ ៨៣៥នាក់ (វិស័យឯកជន) ផ្នែកថែទាំសុខភាពចំនួន ៥០៧ ៥១៨នាក់ ស្រីចំនួន ១៧៦ ១២៣នាក់ (វិស័យឯកជន វិស័យសាធារណៈ និងកម្មករនិយោជិតក្រៅប្រព័ន្ធ)។

### ក. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

#### ១. ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

